ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦

# IMPORTANCE OF INTERNATIONAL ACCOUNTING STANDARDS OF CAMBODIA (CIAS-16)

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS


សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦

# IMPORTANCE OF INTERNATIONAL ACCOUNTING STANDARDS OF CAMBODIA (CIAS-16)


គ្រូណែនាំ៖ ង៉ែត សុខខេម


ជំនាញ គណនេយ្យ


រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ង៉ែត សុខខេម

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃនិងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យ នៅសាកលវិទ្យាល័យ វ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមនាងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យគឺជាជំនាញមួយមានសារៈសំខាន់ផងដែរ សម្រាប់ទីផ្សារបច្ចុប្បន្ន ទាំងអ្នកសិក្សា ក៏ដូចជានៅក្នុងអាជីវកម្ម ទាំងក្នុងវិស័យរដ្ឋ វិស័យឯកជន ឬអង្គការក្រៅរដ្ឋាភិបាល សុទ្ធសឹងតែត្រូវអនុវត្តទាក់ទងនឹងគណនេយ្យដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យ វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យហិរញ្ញវត្ថុ និងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

ហេតុនេះហើយទើបយើងត្រូវស្វែងយល់ និងសិក្សាស្រាវជ្រាវអំពីជំនាញគណនេយ្យ ព្រោះវាមានសារៈសំខាន់ក្នុងការរស់នៅប្រចាំថ្ងៃ សម្រាប់អ្នកសិក្សា ក៏ដូចជាអ្នកធ្វើអាជីវកម្មតូចធំផ្សេងៗ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នរបស់ខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមនាងខ្ញុំ សង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមនាងខ្ញុំសម្រេចចិត្តជ្រើសរើសយកនូវប្រធានបទមួយស្ដីពី «**សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦**»យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់បានយល់ដឹងកាន់តែស៊ីជម្រៅពីការរៀបចំសារណា និងសារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិ ។ ក្រុមនាងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមនាងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមនាងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



ឌុល ស្រីអូន
ID: B22/2089



ហៃ ស៊ីហ័រ
ID: B22/2074



កែ សាន្តអ៊ី
ID: B22/2175



ចាន់ សៀវយាក
ID: B22/2185



សុខ មករា
ID: B22/2145

# សេចក្តីថ្លែងអំណរគុណ

ក្រុមនាងខ្ញុំ ជានិស្សិតនៃសាកលវិទ្យាល័យ វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ៖

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមនាងខ្ញុំ សូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ដាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមនាងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំទាំងអស់គ្នា។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **ខ៉ែត សុខខេម** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមនាងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យ វ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមនាងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមនាងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណះអំណាង**

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យ វ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ **«សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦»** នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធទៅនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវដែលបានលើកឡើងនេះជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ..៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី..២៩.. ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



ឌុល ស្រីអូន

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្នុងពេលបច្ចុប្បន្ននេះរាជរដ្ឋាភិបាល កំពុងតែយកចិត្តទុកដាក់ទៅលើគណនេយ្យភាព និងតម្លាភាពនៃទិន្នន័យហិរញ្ញវត្ថុ ដោយមើលឃើញថានៅក្នុងអាជីវកម្មមួយចំនួន នៅមានចំណុចខ្សោយទៅលើព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុ នៅតែមិនទាន់ត្រឹមត្រូវ ច្បាស់លាស់ និងស្របទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៅឡើយ។

ហេតុនេះហើយ ទើបរាជរដ្ឋាភិបាលខិតខំរិះរកបង្កើតនូវប្រសិទ្ធភាពគណនេយ្យ ដោយធ្វើយ៉ាងណាឱ្យប្រតិបត្តិការហិរញ្ញវត្ថុ ក្នុងអាជីវកម្មទាំងអស់ចេញមកស្របតាមច្បាប់ និងស្តង់ដាអន្តរជាតិ។ បើយើងនិយាយចំពោះអ្នកសិក្សាត្រូវការសិក្សារៀនសូត្រទៅលើមុខជំនាញដែលស្របទៅតាមស្តង់ដា និងមានប្រសិទ្ធភាពខ្ពស់ ហើយមានទីផ្សារការងារទូលំទូលាយ ដូចជានៅក្នុងសាកលវិទ្យាល័យ វ៉ាន់ដា មាននូវមុខជំនាញគណនេយ្យ រួមទាំងមាននូវសាស្ត្រាចារ្យដែលមានវិជ្ជាជីវៈខ្ពស់ក្នុងការបង្រៀន និងកម្មវិធីសិក្សាដែលស្របទៅតាមស្តង់ដា ជាហេតុធ្វើឱ្យសិស្សនិស្សិតដែលបានមកសិក្សានៅទីនេះទទួលបាននូវចំណេះ ជំនាញ ដែលមានប្រសិទ្ធភាពខ្ពស់ ហើយនៅពេលដែលសិស្សនិស្សិតបានបញ្ចប់ការសិក្សានៅទីនេះ មានឱកាសជាច្រើនក្នុងការរកការងារធ្វើ។ ចំណែកឯគ្រប់សហគ្រាសអាជីវកម្មទាំងអស់ មិនថាតែអង្គភាពរដ្ឋក្តី និងអង្គភាពឯកជនក្តី រួមទាំងអាជីវកម្មតូចធំជាច្រើនសុទ្ធសឹងតែត្រូវការនៅទិន្នន័យ ដែលមានភាពត្រឹមត្រូវច្បាស់លាស់ រាល់ការវិភាគលើរបាយការណ៍ហិរញ្ញវត្ថុ ការកត់ត្រាប្រតិបត្តិការប្រចាំថ្ងៃនៅក្នុងអាជីវកម្មរបស់ខ្លួន ហើយរបាយការណ៍ទាំងនោះត្រូវតែអនុលោមហើយស្របទៅតាមស្តង់ដាគណនេយ្យអន្តរជាតិ។ ដោយមើលឃើញថា ការអនុវត្តទៅតាមស្តង់ដាគណនេយ្យអន្តរជាតិ អាចជួយបង្កើនតម្លាភាព និងភាពត្រឹមត្រូវច្បាស់លាស់នៃរបាយការណ៍ហិរញ្ញវត្ថុ និងមិនសូវមានហានិភ័យច្រើនចំពោះទិន្នន័យនៅក្នុងអាជីវកម្ម មិនតែប៉ុណ្ណោះ វាជាចំណែកមួយក្នុងការជួយបង្កើននូវការវិនិយោគពីបណ្តាលក្រុមហ៊ុន ឬស្ថាប័នផ្សេងៗទាំងក្នុង និងក្រៅប្រទេស ចូលរួមកសាងអភិវឌ្ឍអាជីវកម្មជាមួយគ្នាថែមទៀតផង។ ដូចនេះ បានជាក្រុមនាងខ្ញុំមានគោលបំណងក្នុងការបកស្រាយអំពី « **សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦** »។

ជាក់ស្តែងបានជា ក្រុមនាងខ្ញុំធ្វើការសិក្សាស្រាវជ្រាវ និងលើកយកនូវប្រធានបទស្តីពី សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ១៦ ដើម្បីយកមកធ្វើការបកស្រាយឱ្យបានលម្អិតទៅលើប្រវត្តិ ទស្សនៈទូទៅ ទស្សនៈ វិស័យ បេសកកម្ម គោលការណ៍ អត្ថប្រយោជន៍ រួមទាំងបញ្ហាប្រឈម ផលប៉ះពាល់ និងចំណុចសំខាន់ៗផ្សេងៗជាច្រើនទៀត។ ជាពិសេសនៅក្នុងនោះផងដែរ ក្រុមនាងខ្ញុំក៏ចង់បកស្រាយឱ្យបានកាន់តែស៊ីជម្រៅ និងចង់ឱ្យមានការស្វែងយល់ច្បាស់លាស់អំពីសារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ ព្រោះវាមានភាពចាំបាច់ចំពោះអ្នកសិក្សា អាជីវកម្ម និងសង្គមជាតិ។

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវនេះ ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ ពិតជាមានសារៈសំខាន់សម្រាប់ការធានាបាននូវព័ត៌មានហិរញ្ញវត្ថុ ដែលមានភាពច្បាស់លាស់ ស្របតាមច្បាប់ជាតិ និងអន្តរជាតិ។ ដូចនេះ យើងអាចសន្និដ្ឋានបានថា ស្តង់ដាគណនេយ្យអន្តរជាតិ មានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការជំរុញសេដ្ឋកិច្ចសង្គមជាតិឱ្យបានកាន់តែរីកចម្រើន។

# មាតិកា

ទំព័រ


អារម្ភកថា ........................................................................ i

រចនាសម្ព័ន្ធ........................................................................ ii

សេចក្តីថ្លែងអំណរគុណ ........................................................................ iii

អំណះអំណាង ........................................................................ vi

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........................................................................ v

មាតិកា........................................................................ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........................................................................១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ........................................................................២

១.៣ គោលបំណងនៃការស្រាវជ្រាវ........................................................................២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........................................................................២

    ១.៤.១ ទំហំដែនកំណត់........................................................................២

    ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ........................................................................២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ........................................................................២

    ១.៥.១ ការប្រមូលទិន្នន័យតាមបែបគុណវិស័យ ........................................................................៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ........................................................................៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........................................................................៤

## ជំពូកទី២
## សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

២.១ លក្ខណៈទូទៅនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា........................................................................ ៥

    ២.១.១ និយមន័យគណនេយ្យ និងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ........................................................................ ៥

    ២.១.២ ប្រវត្តិនៃគណនេយ្យ និងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា........................................................................ ៦

    ២.១.៣ ទ្រឹស្តីនៃគណនេយ្យ និងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ........................................................................ ៦

២.២ ទស្សនៈទូទៅទៅលើស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា........................................................................ ៦

    ២.២.១ វិសាលភាពនៃការអនុវត្ត........................................................................៧

    ២.២.២ គោលការណ៍ និងចំណុចសំខាន់........................................................................៧

        ក.ការទទួលស្គាល់ ........................................................................៨

        ខ.ការវាស់វែង ........................................................................៩

        គ.ការលែងទទួលស្គាល់ ........................................................................៩

ឃ.ការលាតត្រដាង ........................................................................................................១០
២.៣ សារៈសំខាន់ និងផលប៉ះពាល់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា.................................. ១២

## ជំពូកទី៣

## សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ នៅក្នុងស្ថាប័ននិយ័តករគណនេយ្យ និងសវនកម្ម

៣.១ ស្ថានភាពទូទៅរបស់និយ័តករគណនេយ្យ និងសវនកម្ម...................................................... ១៣
៣.១.១ ប្រវត្តិរបស់និយ័តករគណនេយ្យ និងសវនកម្ម ...........................................................១៦
៣.១.២ ទស្សនវិស័យ និងបេសកកម្មរបស់និយ័តករគណនេយ្យ និងសវនកម្ម ................... ១៧
៣.១.៣ រចនាសម្ព័ន្ធ និងតួនាទីរបស់និយ័តករគណនេយ្យ និងសវនកម្ម ............................ ២០
៣.២ ទស្សនៈរបស់និយ័តករគណនេយ្យ និងសវនកម្មទៅលើ (CIAS-16) ..................................... ២០
៣.២.១ វិសាលភាពនៃការអនុវត្ត.................................................................................... ២១
៣.២.២ គោលការណ៍ និងចំណុចសំខាន់ ............................................................................ ២១
ក.ការទទួលស្គាល់ ..........................................................................................២៣
ខ.ការវាស់វែង ................................................................................................. ២៤
គ.ការលែងទទួលស្គាល់ .................................................................................. ២៥
ឃ.ការលាតត្រដាង........................................................................................... ២៦
៣.២.៣ សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ ........................................ ២៦
ក.ការធានាភាពត្រឹមត្រូវ និងសុចរិតនៃរបាយការណ៍ហិរញ្ញវត្ថុ ................................២៧
ខ.ការជំរុញការវិនិយោគ ................................................................................... ២៩
គ.ការគ្រប់គ្រងប្រសិទ្ធភាពទ្រព្យសកម្ម...........................................................................៣០
៣.៣ ផលប៉ះពាល់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ចំពោះប្រតិបត្តិការអាជីវកម្ម ............៣២

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង................................................................................................. ៣៤
៤.២ ការវិភាគលើចំណុចខ្សោយ ............................................................................................. ៣៥

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន .............................................................................................................. ៣៦
៥.២ ការផ្តល់អនុសាសន៍ .........................................................................................................៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងពេលបច្ចុប្បន្ននេះ ប្រទេសនៅលើសកលលោក រួមទាំងប្រទេសកម្ពុជាយើងមួយផងដែរ គ្រប់ក្រុមហ៊ុន សហគ្រាសតូចធំទាំងអស់ មិនថាអង្គភាពរដ្ឋក្តី ឯកជនក្តី ឬអង្គភាពក្រៅរដ្ឋាភិបាលក្តី រាល់ការបង្កើតអាជីវកម្មទាំងអស់របស់ពួកគេ គឺក្នុងគោលបំណងចង់ទទួលបាននូវប្រាក់ចំណេញ។ ហើយទទឹមនឹងនោះ គ្រប់អង្គភាពទាំងអស់សុទ្ធតែត្រូវការនូវផ្នែកផ្សេងៗគ្នាជាច្រើន ដែលជាចំណែកក្នុងការចូលរួមជួយអភិវឌ្ឍន៍អាជីវកម្ម របស់ក្រុមហ៊ុនមានដំណើរការទៅមុខ។ ក្នុងនោះក៏មាននូវផ្នែកគណនេយ្យមួយ ដែលបានដើរតួនាទីយ៉ាងសកម្ម ក្នុងដំណើរការអាជីវកម្ម ហើយគណនេយ្យជាអ្នកធ្វើការវិភាគ កត់ត្រាគ្រប់ប្រតិបត្តិការ រៀបចំឯកសាររបាយការណ៍ហិរញ្ញវត្ថុ និងទិន្នន័យផ្សេងៗទៀត ដែលកើតមានឡើងជាប្រចាំថ្ងៃនៅក្នុងអង្គភាព។ ទោះជាយ៉ាងណាក៏ដោយ គ្រប់ការវិភាគ ការកត់ត្រា ការរៀបចំឯកសារ និងរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងអង្គភាពនីមួយៗ មិនប្រាកដថាទទួលបាននូវទិន្នន័យដែលត្រឹមត្រូវ ច្បាស់លាស់ទាំងអស់នោះទេ ក៏នៅតែមាននូវចំណុចខ្វះខាតមួយចំនួនផងដែរ។

ដោយមើលឃើញថា នៅក្នុងអង្គភាពអាជីវកម្មមួយចំនួន បើយោងទៅតាមការសង្កេតមើលទៅលើព័ត៌មាននៃរបាយការណ៍ហិរញ្ញវត្ថុ គឺថានៅតែមិនទាន់ត្រឹមត្រូវ ច្បាស់លាស់ និងសមស្របទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៅឡើយ ទើបរាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់ទៅលើគណនេយ្យភាព និងតម្លាភាពនៃទិន្នន័យហិរញ្ញវត្ថុ ហើយរាជរដ្ឋាភិបាលខិតខំរិះរក និងបង្កើតនូវប្រសិទ្ធភាពគណនេយ្យ ដោយធ្វើយ៉ាងណាឱ្យប្រតិបត្តិការហិរញ្ញវត្ថុក្នុងអាជីវកម្មទាំងអស់ចេញមកស្របតាមច្បាប់ និងស្តង់ដាអន្តរជាតិ។ នៅពេលដែលអង្គភាពអាជីវកម្មទាំងអស់ អនុវត្តតាមច្បាប់នៃស្តង់ដាគណនេយ្យអន្តរជាតិបានត្រឹមត្រូវ ច្បាស់លាស់ ទើបមិនសូវមានកំហុសខុសឆ្គង និងមិនមានហានិភ័យ ឬក៏បញ្ហាប្រឈមច្រើនដែលកើតឡើងចំពោះទិន្នន័យហិរញ្ញវត្ថុនៅក្នុងអង្គភាពអាជីវកម្មរបស់ពួកគេ ហើយមិនត្រឹមតែប៉ុណ្ណោះវាជាចំណែកដ៏សំខាន់មួយ ក្នុងការជួយបង្កើននូវការវិនិយោគពីគ្រប់បណ្តាលសហគ្រាស ឬក្រុមហ៊ុនផ្សេងៗជាច្រើន ចូលរួមកសាងអភិវឌ្ឍន៍អាជីវកម្មជាមួយគ្នាបានថែមទៀតផង។ បើយើងនិយាយចំពោះអ្នកសិក្សា ក៏ដូចជាសិស្សនិស្សិតវិញ គឺត្រូវការសិក្សារៀនសូត្រទៅលើមុខជំនាញណាដែលស្របទៅតាមស្តង់ដា និងមានប្រសិទ្ធភាពខ្ពស់ ហើយរួមទាំងមានទីផ្សារការងារទូលំទូលាយដូចជានៅក្នុងសាកលវិទ្យាល័យ វ៉ាន់ដា មានការបណ្តុះបណ្តាលលើមុខជំនាញគណនេយ្យ ចំណែកឯសាស្ត្រាចារ្យមានវិជ្ជាជីវៈខ្ពស់ក្នុងការបង្រៀន និងកម្មវិធីសិក្សាដែលសមស្របទៅតាមស្តង់ដា ជាហេតុធ្វើឱ្យសិស្សនិស្សិតដែលបានមកសិក្សានៅទីនេះទទួលបាននូវចំណេះ ជំនាញ ដែលមានប្រសិទ្ធភាពខ្ពស់ ហើយនៅពេលដែលសិស្សនិស្សិតបានបញ្ចប់ការសិក្សានៅទីនេះ មានឱកាសជាច្រើនក្នុងការស្វែងរកការងារធ្វើ។

ជាការពិតណាស់ ដោយសារតែបានមើលឃើញនូវអត្ថប្រយោជន៍ និងសារៈសំខាន់ទាំងនេះហើយ ទើបក្រុមនាងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី «សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦» យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការអនុវត្តតាមច្បាប់នៃស្តង់ដាគណនេយ្យអន្តរជាតិ គឺពិតជាមានអត្ថប្រយោជន៍ និងសារៈសំខាន់ខ្លាំងណាស់ ចំពោះសហគ្រាស អាជីវកម្មតូចធំជាច្រើន ដែលជាចំណែកមួយក្នុងការជួយធ្វើឱ្យអាជីវកម្មមានភាពរីកចម្រើន។ អាស្រ័យហេតុនេះហើយ ទើបបានជាយើងត្រូវតែអនុវត្តន៍ទៅតាមស្តង់ដាគណនេយ្យអន្តរជាតិ ដើម្បីជៀសវាងការកើតមាននូវហានិភ័យ ឬបញ្ហាប្រឈមផ្សេងៗទៅលើទិន្នន័យហិរញ្ញវត្ថុនៅក្នុងអាជីវកម្ម ហើយថែមទាំងជួយជំរុញក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិឱ្យកាន់តែមានភាពរីកចម្រើនថែមទៀតផង។ ដើម្បីបានជាទុន និងជាកញ្ចក់ឆ្លុះបញ្ចាំងអំពីទិដ្ឋភាពទូទៅជុំវិញនៃប្រធានបទ សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ១៦ យើងគួរគប្បីស្វែងយល់ពីសំណួរមួយចំនួនខាងក្រោមជាមុនសិន។

១. តើនិយ័តករគណនេយ្យ និងសវនកម្ម មានទស្សនៈយ៉ាងដូចម្តេចខ្លះចំពោះការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ ?

២. តើស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ មានសារៈសំខាន់ និងផលប៉ះពាល់អ្វីខ្លះទៅលើរបាយការណ៍ហិរញ្ញវត្ថុចំពោះប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីចង់ឱ្យយើងស្វែងយល់អំពី៖

- យល់ដឹងកាន់តែច្បាស់ទៅលើការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦
- យល់ដឹងទាក់ទងទៅនឹងសារៈសំខាន់ និងផលប៉ះពាល់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ ទៅលើរបាយការណ៍ហិរញ្ញវត្ថុចំពោះប្រតិបត្តិការអាជីវកម្មនៅកម្ពុជា។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ទិន្នន័យដែលយកមកសិក្សាស្រាវជ្រាវនេះ បានមកពីការស្រាវជ្រាវតាមរយៈគេហៈទំព័ររបស់និយ័តករគណនេយ្យ និងសវនកម្ម ដែលសព្វថ្ងៃស្ថាប័ននេះមានទីតាំងស្ថិតនៅផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ក៏ដូចជាឯកសារពាក់ព័ន្ធដែលមាននៅក្នុងសៀវភៅពុម្ពនៃសាកលវិទ្យាល័យវ៉ាន់ដាផងដែរ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវខាងលើនេះ ក្រុមនាងខ្ញុំ បានយកមកសិក្សាត្រឹមតែ «សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦» តែប៉ុណ្ណោះក្នុងចំណោមស្តង់ដាដែលបានអនុម័តនៅក្នុងប្រទេសកម្ពុជា។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.១ ការប្រមូលទិន្នន័យតាមបែបគុណវិស័យ

ការសិក្សាស្រាវជ្រាវ ត្រូវបានប្រមូលទិន្នន័យតាមបែបគុណវិស័យដែលផ្តោតទៅលើការវិភាគ ការពិភាក្សាជាក្រុម ការស្រាវជ្រាវតាមរយៈគេហៈទំព័ររបស់និយ័តករគណនេយ្យ និងសវនកម្ម ការស្រាវជ្រាវទិន្នន័យពីឯកសារពាក់ព័ន្ធដែលមាននៅក្នុងសៀវភៅពុម្ពនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលទាក់ទងទៅនឹងប្រធានបទ ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់ពីសារៈសំខាន់ និងផលប៉ះពាល់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃ

កម្ពុជា១៦ ទៅលើរបាយការណ៍ហិរញ្ញវត្ថុចំពោះប្រតិបត្តិការអាជីវកម្មនៅកម្ពុជា។

សម្រាប់សំណួរទី១៖ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានប្រមូលទិន្នន័យតាមបែបគុណវិស័យដែលផ្តោតទៅលើការវិភាគ ការស្រាវជ្រាវទិន្នន័យពីកម្រងឯកសារពាក់ព័ន្ធ ការស្រាវជ្រាវតាមរយៈគេហៈទំព័របណ្តាញសង្គមរបស់ស្ថាប័នផ្ទាល់ ការដកស្រង់នូវឯកសារមេរៀនដែលទាក់ទងជាមួយប្រធានបទ និងធ្វើការសាកសួរព័ត៌មានបន្ថែមពីលោកគ្រូណែនាំ។

សម្រាប់សំណួរទី២៖ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានប្រមូលទិន្នន័យតាមបែបគុណវិស័យដែលផ្តោតទៅលើការវិភាគ ការស្រាវជ្រាវទិន្នន័យពីកម្រងឯកសារពាក់ព័ន្ធ ការស្រាវជ្រាវតាមរយៈគេហៈទំព័របណ្តាញសង្គមរបស់ស្ថាប័នផ្ទាល់ ការដកស្រង់នូវឯកសារមេរៀនដែលពាក់ព័ន្ធជាមួយប្រធានបទ និងធ្វើការសាកសួរព័ត៌មានបន្ថែមពីលោកគ្រូណែនាំ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះពិតជាបានផ្តល់នូវសារៈសំខាន់ និងអត្ថប្រយោជន៍យ៉ាងច្រើនចំពោះ៖

### ១.៦.១ ចំពោះក្រុមអ្នកស្រាវជ្រាវផ្ទាល់

- ជួយបង្កើននូវចំណេះដឹង ជំនាញ ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង
- ចេះធ្វើការជាក្រុម ចេះយោគយល់ និងជួយដោះស្រាយបញ្ហានៅក្នុងក្រុម
- មានទំនួលខុសត្រូវលើកិច្ចការស្រាវជ្រាវ និងបានពង្រឹងនូវការយល់ដឹងបានច្រើន
- យល់ដឹងកាន់តែច្បាស់ទៅលើការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦
- យល់ដឹងទាក់ទងទៅនឹងសារៈសំខាន់ និងផលប៉ះពាល់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ ចំពោះប្រតិបត្តិការអាជីវកម្មនៅកម្ពុជា។

### ១.៦.២ ចំពោះស្ថាប័ន

- យល់ដឹងពីចំណុចខ្លាំង និងចំណុចខ្សោយដើម្បីធ្វើការកែលម្អនូវចំណុចខ្វះខាត និងអភិវឌ្ឍន៍បន្ថែម
- បង្កើនទំនុកចិត្តពីអតិថិជន និងអ្នកវិនិយោគ
- ផ្សព្វផ្សាយពីវិសាលភាព និងកេរ្តិ៍ឈ្មោះរបស់ស្ថាប័ន។

### ១.៦.៣ ចំពោះសង្គម

- ជួយជាចំណេះដឹងមួយចំនួនដល់ការស្រាវជ្រាវ
- ចងក្រងជាឯកសារសម្រាប់សិស្ស និស្សិតជំនាន់ក្រោយធ្វើការសិក្សាស្រាវជ្រាវបន្ត។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជំពូកទី១ ៖ ជំពូកនេះបាននិយាយអំពី លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី២ ៖ បានលើកឡើងនូវលក្ខណៈទូទៅ ទស្សនៈទូទៅ និងអត្ថប្រយោជន៍នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ ។

ជំពូកទី៣ ៖ បាននិយាយទៅលើស្ថានភាពទូទៅ ទស្សនៈទូទៅ ការអនុវត្ត សារៈសំខាន់ និងផលប៉ះពាល់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ ទៅលើរបាយការណ៍ហិរញ្ញវត្ថុចំពោះប្រតិបត្តិការអាជីវកម្មនៅកម្ពុជា នៅក្នុងស្ថាប័ននិយ័តករគណនេយ្យ និងសវនកម្ម។

ជំពូកទី៤ ៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

# ជំពូកទី២
# សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

## ២.១ លក្ខណៈទូទៅនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

### ២.១.១ និយមន័យគណនេយ្យ និងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

គណនេយ្យ គឺជាមុខវិជ្ជាមួយបែបវិទ្យាសាស្ត្រដែលសិក្សាលម្អិតអំពីរបៀបកត់ត្រា ការរកស៊ី ឬប្រតិបត្តិការសេដ្ឋកិច្ចក្នុងគោលបំណងសរុបតួរលេខនៃបណ្តាខ្ទង់គណនីទាំងប្រាំក្រុម ទៅតំឡើងរបាយការណ៍ហិរញ្ញវត្ថុ (Income Statement or Balance sheet)[1]។

ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា (Cambodian International Accounting Standards - CIAS) គឺជាសំណុំនៃស្តង់ដាគណនេយ្យដែលប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ដើម្បីកំណត់ពីនីតិវិធី និងកំណត់គោលការណ៍សម្រាប់ការរៀបចំក្នុងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ[2]។

### ២.១.២ ប្រវត្តិនៃគណនេយ្យ និងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

**- ប្រវត្តិនៃគណនេយ្យ៖**

កាលពីដើមឡើយពាណិជ្ជករទាំងឡាយ ពុំមានរបៀបរបបនៃការកត់ត្រាទិន្នន័យគណនេយ្យរបស់គេឱ្យបានត្រឹមត្រូវនោះទេ មិនត្រឹមតែប៉ុណ្ណោះវាមានការមិនឯកភាពគ្នារវាងគណនេយ្យករ និងគណនេយ្យករផងដែរ។ លុះដល់ជំនាន់លោក មី សែលលែនជឺឡូ (Michelengelo) (1475-1564) នៅប្រទេសអ៊ីតាលី លោក ហ្វ្រ លុយកាផាស៊ីអូលី (Friar Lucpacioli) ដែលជាព្រះសង្ឃខាងព្រះហ្វ្រង់ស៊ុល និងជាគណិតវិទូម្នាក់បានបង្កើតនូវរូបមន្តមួយដោយផ្អែកលើសមីការគណិតវិទ្យាគឺប្រពន្ធ័ចុះបញ្ជីទ្វេរភាគ (Double-Entry Bookkeeping) នៅឆ្នាំ ១៥៩៤ ដើម្បីសម្រួល ដល់ពាណិជ្ជករទាំងឡាយនៅទីក្រុង វេនីស (vennice) ក្នុងសតវត្សទី ១៥។ លោកបានបង្កើតរូបមន្តមួយនេះឡើង ដើម្បីជួយពាណិជ្ជករឱ្យយល់ដឹងទូលំ ទូលាយលើស្ថានភាពហិរញ្ញវត្ថុរបស់ អាជីវកម្មពួកគេ។ លោកបានចាប់ផ្តើម ជាមួយ និង គោលគំនិត ប្រភពធនធានសេដ្ឋកិច្ចត្រូវស្មើនិងទ្រព្យរបស់ម្ចាស់។ ក្រោយមកមិនយូរប៉ុន្មានលោក Friar Lucapacioli បានយល់ឃើញថាប្រភពធនធានសេដ្ឋកិច្ចមិនសុទ្ធតែត្រូវស្មើនឹងទ្រព្យរបស់ម្ចាស់ផ្ទាល់នោះទេគឺអាចបានមកពីការខ្ចីទុនពីប្រភពខាងក្រៅដូចជា ធនាគារ មីក្រូហិរញ្ញវត្ថុ សាច់ញ្ញាតិដែលយើងអាច ហៅយ៉ាងខ្លីបានថា បំណុល។ ដូចនេះគាត់បានធ្វើការកែប្រែសមីការទៅជា «ទ្រព្យសកម្ម = បំណុល + ទ្រព្យម្ចាស់» ។ ដែលពេលនោះទ្រព្យសម្បត្តិត្រូវបានកំណត់ថា ជាអត្ថប្រយោជន៍នាពេលអនាគតដែលកើតឡើងពីប្រតិបត្តិការអតីតកាលរីឯបំណុលកើនឡើង ឬថយចុះអាស្រ័យលើសកម្មភាពដំណើរការអាជីវកម្ម។ អង្គភាពអាជីវកម្មប្រើប្រាស់នូវធាតុទាំងនេះ ដើម្បីរកប្រាក់ចំណេញ ឬសងបំណុលគេ សកម្មភាពទាំងនេះអាចធ្វើឱ្យប្រាក់ចំណេញកើនឡើង ឬថយចុះយោងទៅតាមសមីការនេះ។ របាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព ត្រូវបានបង្ហាញពីប្រភពធនធានសេដ្ឋកិច្ច និងប្រកាសប្រភពធនធានទាំងនោះនៅខណៈពេលណាមួយ។ ចាប់តាំងពីពេលនោះមកការកត់ត្រារបៀបនេះក៏បានអនុវត្តន៍បន្តិចម្តងៗរហូតក្លាយទៅជាការកត់ត្រាដែលមានក្បួនខ្នាតត្រឹមត្រូវដែលហៅថា « គណនេយ្យ » ព្រមទាំងមានគំរូស្តង់ដាសម្រាប់អនុវត្តន៍ទៀត

[1] វិទ្យាស្ថានវ៉ាន់ដា (2022). *Basic Financial Accounting ភាគ១.* បោះពុម្ពលើកទី១១. ទំព័រទី៧២. ២៣២ទំព័រ. ភ្នំពេញ។

[2] ភ្នំពេញបុស្តិ៍. (2020,October 26). *ហេតុអ្វីបានជាស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាមានសារៈសំខាន់?* Retrieved from https://m.postkhmer.com (Accessed 02.04.25)

ផង។ លុះដល់ឆ្នាំ ១៩៤១ American Instate of certified public Accounting (AICPA) បានអះអាងថា គណនេយ្យ គឺជាប្រភពព័ត៌មានដ៏សំខាន់ដែលប្រាប់នូវស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព ដើម្បីប្រើប្រាស់ជាជំនួយដ៏ប្រសើរបំផុតសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត[3]។

**- ប្រវត្តិស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា៖**

អំឡុងទសវត្សរ៍ ១៩៩០ បន្ទាប់ពីសង្គ្រាម និងការបង្រួបបង្រួមប្រទេសវិញ កម្ពុជាបានចាប់ផ្តើមអភិវឌ្ឍន៍នូវប្រព័ន្ធគណនេយ្យឡើងវិញ។ មុនឆ្នាំ ២០០០ កម្ពុជាមិនមានស្តង់ដាទូទៅសម្រាប់គណនេយ្យទេ។ នៅក្នុងក្រុមហ៊ុន និងអង្គការផ្សេងៗប្រើប្រាស់គណនេយ្យខ្លួនឯង ដោយមិនមានគោលការណ៍ស្ថិតស្ថេរនោះឡើយ។ នៅឆ្នាំ២០០៣ ក្រុមប្រឹក្សាជាតិគណនេយ្យ (National Accounting Council - NAC) ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសម្រេចអនុម័ត និងដាក់ឱ្យប្រើប្រាស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ដែលផ្អែកទៅលើស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standards - IAS) ហើយចាប់តាំងពីឆ្នាំ ២០០៩ រហូតមកដល់បច្ចុប្បន្ន CIAS ត្រូវបានធ្វើបច្ចុប្បន្នភាពបន្តបន្ទាប់ដើម្បីឱ្យស្របទៅនឹងស្តង់ដារបស់អង្គការ International Accounting Standards Board (IASB)។ នីតិវិធីនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបន្ថែម និងកែប្រែដើម្បីធានាបាននូវភាពច្បាស់លាស់ និងភាពជឿទុកចិត្តបាននៃទិន្នន័យហិរញ្ញវត្ថុ[4]។ CIAS ត្រូវបានកាត់បន្ថយឱ្យសមស្របទៅនឹងអាជីវកម្មតូច និងមធ្យម (SMEs) ដោយមានការផ្សាភ្ជាប់ជាមួយស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់ SMEs (IFRS for SMEs)។ រដ្ឋាភិបាលកម្ពុជា និងស្ថាប័នគណនេយ្យក្នុងស្រុកបានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ដើម្បីលើកកម្ពស់នូវការយល់ដឹង និងការអនុវត្តស្តង់ដានេះនៅក្នុងសហគ្រិនភាព និងវិស័យហិរញ្ញវត្ថុ។

ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា (Cambodian International Accounting Standards - CIAS) ត្រូវបានបង្កើតឡើង ដើម្បីអភិវឌ្ឍប្រព័ន្ធគណនេយ្យ និងការរាយការណ៍ហិរញ្ញវត្ថុនៅកម្ពុជាឱ្យមានតម្លាភាព ធានានូវភាពត្រឹមត្រូវ និងស្តង់ដាទូលំទូលាយតាមគោលការណ៍អន្តរជាតិ។ យើងអាចសង្ឃឹមថា ក្នុងអនាគត CIAS នឹងបន្តអភិវឌ្ឍន៍ និងសម្របសម្រួលបន្ថែមដើម្បីត្រៀមលក្ខណៈសម្រាប់ការរួមបញ្ចូលគ្នានៅលើវេទិកាសេដ្ឋកិច្ចអន្តរជាតិ។

### ២.១.៣ ទ្រឹស្តីនៃគណនេយ្យ និងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

គណនេយ្យ គឺជាមុខវិជ្ជាមួយបែបវិទ្យាសាស្ត្រដែលសិក្សាលម្អិតអំពីរបៀបកត់ត្រាការរកស៊ី ឬប្រតិបត្តិការសេដ្ឋកិច្ចក្នុងគោលបំណងសរុបតួរលេខនៃបណ្តាខ្ទង់គណនីទាំងប្រាំក្រុមទៅជំឡើងរបាយការណ៍ហិរញ្ញវត្ថុ (Income Statement or Balance sheet)[5]។

ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា (Cambodian International Accounting Standards - CIAS) គឺជាសំណុំនៃស្តង់ដាគណនេយ្យ ដែលប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាដើម្បីកំណត់ពីនីតិវិធី និងកំណត់គោលការណ៍សម្រាប់ការរៀបចំក្នុងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ[6]។

---

[3] Facebook Page. Khmer Next Generation. (2024, September 16). *ប្រវត្តិគណនេយ្យ.* Retrieved from https://www.facebook.com/share/p/1AhtCkoxgG/?mibextid=wwXIfr (Accessed 02.04.25)

[4] ភ្នំពេញប៉ុស្តិ៍.( 2020,October 26). *ហេតុអ្វីបានជាស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាមានសារៈសំខាន់?* Retrieved from https://m.postkhmer.com (Accessed 02.04.25)

[5] វិទ្យាស្ថានវ៉ាន់ដា (2022). Basic Financial Accounting ភាគ១ បោះពុម្ពលើកទី១១ ទំព័រទី.៧២ ២៣២ទំព័រ. ភ្នំពេញ។

[6] ភ្នំពេញប៉ុស្តិ៍. (2020, October 26). *ហេតុអ្វីបានជាស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាមានសារៈសំខាន់?* Retrieved from https://m.postkhmer.com (Accessed 02.04.25)

## ២.២ ទស្សនៈទូទៅនៅលើស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

### ២.២.១ វិសាលភាពនៃការអនុវត្ត

ការអនុវត្ត CIAS បានផ្តល់នូវការបង្ហាញព័ត៌មានដែលមានភាពត្រឹមត្រូវ ច្បាស់លាស់ និងអាចជឿទុកចិត្តបាន ហើយប្រកបដោយតម្លាភាព និងការកត់ត្រាត្រឹមត្រូវទៅតាមវិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការរាយការណ៍ហិរញ្ញវត្ថុ ដែលអាចធានាបានថាវាកំពុងបង្ហាញពីព័ត៌មានដោយគ្មានការបំភាន់នូវប្រតិបត្តិការផ្សេងៗរបស់ក្រុមហ៊ុន ឬអង្គភាពទាំងនោះ។ លើសពីទៅទៀតនេះ ការអនុវត្ត CIAS មិនត្រឹមតែជួយធ្វើឱ្យរបាយការណ៍ហិរញ្ញវត្ថុប្រកបដោយតម្លាភាពប៉ុណ្ណោះទេ ប៉ុន្តែវាបានជួយជំរុញឱ្យមាននូវការវិនិយោគកាន់តែច្រើនឡើងៗថែមទៀតផង ជាពិសេសវាក៏ជាកត្តាសំខាន់មួយដែលបានធ្វើឱ្យសេដ្ឋកិច្ចនៅក្នុងប្រទេសជាតិមានការរីកចម្រើនជាលំដាប់ផងដែរ[7]។ នៅការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាមានវិសាលភាពនៅលើវិស័យមួយចំនួនដូចខាងក្រោម៖

- លើវិស័យអាជីវកម្ម សហគ្រាសធំៗ និងក្រុមហ៊ុនដែលចុះបញ្ជីក្នុងទីផ្សារមូលបត្រ ត្រូវអនុវត្ត CIAS ដើម្បីបង្កើនភាពទុកចិត្តរបស់អ្នកវិភាគហិរញ្ញវត្ថុ និងវិនិយោគិនអន្តរជាតិ។ សហគ្រាសតូច និងមធ្យម (SMEs) អាចប្រើស្តង់ដាសម្រាប់ SMEs (CIAS for SMEs) ដែលសមស្របជាមួយការចំណាយកាន់តែតិចក្នុងការទប់ស្កាត់កំហុសគណនេយ្យ។
- លើវិស័យសាធារណៈ និងរដ្ឋាភិបាល ដោយការអនុវត្តស្តង់ដាគណនេយ្យអាចជួយបង្កើនភាពងាយស្រួលដល់រដ្ឋក្នុងការសងបំណុល និងគ្រប់គ្រងថវិកាជាតិប្រកបដោយភាពប្រសើរ។ វាបានជួយដល់ស្ថាប័នរដ្ឋ ដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ឬនិយ័តករគណនេយ្យ និងសវនកម្ម (ACAR) ដើម្បីអនុវត្តស្តង់ដាបានច្បាស់លាស់។
- លើវិស័យវិនិយោគ និងស្ថាប័នហិរញ្ញវត្ថុ វាជួយធានាបាននូវភាពជាក់ស្តែងនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីបង្កើនការទុកចិត្តពីភាគីពាក់ព័ន្ធ។
- លើវិស័យគណនេយ្យ និងសវនកម្ម ដោយក្រុមហ៊ុនសវនកម្ម (Audit firms) និងគណនេយ្យករត្រូវតែអនុវត្ត CIAS ដើម្បីធានានូវភាពស្មោះត្រង់ និងការធ្វើបញ្ជីបានត្រឹមត្រូវ ហើយមានប្រសិទ្ធ។ ស្ថាប័នសិក្សាគណនេយ្យដូចជា KICPAA, ACCA, CPA ត្រូវការអនុវត្ត CIAS ដើម្បីអប់រំគណនេយ្យករឱ្យស្របតាមបទដ្ឋានអន្តរជាតិ។

### ២.២.២ គោលការណ៍ និងចំណុចសំខាន់

#### ក.ការទទួលស្គាល់

ការទទួលស្គាល់ (Recognition) នៅក្នុងការអនុវត្ត CIAS បានធ្វើឱ្យការប្រើប្រាស់គោលការណ៍គណនេយ្យស្របតាមស្តង់ដាអន្តរជាតិ ដើម្បីធានាថាក្រុមហ៊ុនអាចរាយការណ៍ពីប្រតិបត្តិការហិរញ្ញវត្ថុ ដែលមានព័ត៌មានជាក់លាក់ ត្រឹមត្រូវ និងអាចប្រៀបធៀបនូវរបាយការណ៍ហិរញ្ញវត្ថុជាមួយក្រុមហ៊ុនអន្តរជាតិផ្សេងទៀត[8]។ គោលការណ៍សំខាន់ៗនៃការទទួលស្គាល់ក្នុងការអនុវត្ត CIAS ៖

[7] និយ័តករគណនេយ្យ និងសវនកម្ម. (2015,December 16). *ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា.* Retrieved from https://www.acar.gov.kh (Accessed 02.04.25)

[8] និយ័តករគណនេយ្យ និងសវនកម្ម.(2015,December 16). *ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា.* Retrieved from https://www.acar.gov.kh (Accessed 02.04.25)

- ការទទួលស្គាល់ចំណូល (Revenue Recognition) ដោយចំណូលត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនបានផ្តល់សេវាកម្មឬទំនិញដល់អតិថិជន ហើយអតិថិជនមានកាតព្វកិច្ចចាំបាច់ត្រូវបង់ប្រាក់ ហើយចំណូលត្រូវបានវាស់វែងតាមតម្លៃដែលអាចទទួលបានពីទំនិញ ឬសេវាកម្មដែលបានផ្តល់។
- ការទទួលស្គាល់ការចំណាយ (Expense Recognition) គឺការចំណាយត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនបានទទួលប្រយោជន៍ពីការចំណាយនោះ ឬនៅពេលដែលការចំណាយនោះត្រូវបានធ្វើឡើង ហើយការចំណាយត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ នៅពេលដែលវាបង្កើតបាននូវការបាត់បង់ ឬកាត់បន្ថយទ្រព្យសកម្ម។
- ការទទួលស្គាល់ទ្រព្យសកម្ម (Asset Recognition) គឺទ្រព្យសកម្មត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានការគ្រប់គ្រងទៅលើទ្រព្យសកម្មនោះ ហើយទ្រព្យសកម្មនោះអាចនាំមកនូវប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត។ ដោយទ្រព្យសកម្មត្រូវបានវាស់វែងតាមតម្លៃដែលអាចទទួលបាន ឬតម្លៃដើម។
- ការទទួលស្គាល់បំណុល (Liability Recognition) ដោយបំណុលត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចចាំបាច់ត្រូវបង់ប្រាក់ ឬផ្តល់សេវាកម្មនាពេលអនាគត ដែលកើតចេញពីប្រតិបត្តិការកន្លងមក។ ហើយបំណុលត្រូវបានវាស់វែងតាមតម្លៃដែលត្រូវបង់។

សារៈសំខាន់នៃការទទួលស្គាល់នៅក្នុង CIAS៖

- ភាពជឿជាក់នៃព័ត៌មានហិរញ្ញវត្ថុ គឺជាកត្តាសំខាន់សម្រាប់អ្នកវិនិយោគ ឥណទាន និងភាគីពាក់ព័ន្ធផ្សេងទៀត។
- ការបង្កើនភាពជឿជាក់នៃទីផ្សារហិរញ្ញវត្ថុកម្ពុជា គឺជាកត្តាសំខាន់សម្រាប់ការទាក់ទាញការវិនិយោគពីបរទេស។

សរុបមក ការទទួលស្គាល់នៅក្នុង CIAS គឺជាផ្នែកសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុ ដែលធានាថាក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជាអាចរាយការណ៍ពីប្រតិបត្តិការហិរញ្ញវត្ថុប្រកបដោយយុត្តិធម៌ ត្រឹមត្រូវ និងអនុវត្តស្របតាមស្តង់ដាគណនេយ្យដែលទទួលស្គាល់ជាអន្តរជាតិ។

### ខ.ការវាស់វែង

ការវាស់វែង (Measurement) គឺជាផ្នែកមួយដ៏សំខាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងការរាយការណ៍ហិរញ្ញវត្ថុ។ ខាងក្រោមនេះ គឺជាចំណុចសំខាន់ៗនៃការវាស់វែងនៅក្នុង CIAS៖

### ១. វិធីសាស្ត្រនៃការវាស់វែង

- តម្លៃប្រវត្តិសាស្ត្រ (Historical Cost)៖ ទ្រព្យសកម្ម និងបំណុលត្រូវបានកត់ត្រាតាមតម្លៃដែលបានទិញ ឬបង់នៅពេលទិញ[9]។
- តម្លៃបច្ចុប្បន្ន (Present Value)៖ រួមមានតម្លៃទីផ្សារ (Fair Value) តម្លៃបច្ចុប្បន្នសុទ្ធ (Net Realizable Value) និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ (Present Value of Cash Flows)។

### ២. ការវាយតម្លៃទ្រព្យសកម្ម និងបំណុល

[9] និយ័តករគណនេយ្យ និងសវនកម្ម.(2015,December 16). *ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា.* Retrieved from https://www.acar.gov.kh (Accessed 02.04.25)

- ទ្រព្យសកម្ម ត្រូវបានវាយតម្លៃដោយផ្អែកលើតម្លៃប្រវត្តិសាស្ត្រ ឬតម្លៃទីផ្សារអាស្រ័យលើលក្ខខណ្ឌ និងកាលៈទេសៈ។
- បំណុល ត្រូវបានវាយតម្លៃតាមតម្លៃប្រវត្តិសាស្ត្រ ឬតម្លៃបច្ចុប្បន្ននៃការទូទាត់។

### ៣. ការវាយតម្លៃប្រាក់ចំណូល និងការចំណាយ

- ប្រាក់ចំណូល ត្រូវបានកត់ត្រានៅពេលដែលក្រុមហ៊ុនបានបញ្ចប់ការផ្តល់សេវា ឬទំនិញដល់អតិថិជន និងអាចវាស់វែងបានដោយជឿជាក់។
- ការចំណាយ ត្រូវបានកត់ត្រានៅពេលដែលក្រុមហ៊ុនបានចំណាយ ឬទទួលយកការប្រើប្រាស់ទ្រព្យសកម្ម ឬសេវាកម្ម។

### ៤. ការវាយតម្លៃឡើងវិញ និងការកែតម្រូវ

- ក្រុមហ៊ុនត្រូវធ្វើការវាយតម្លៃឡើងវិញនៃទ្រព្យសកម្ម និងបំណុលជាប្រចាំ ដើម្បីធានាថាតម្លៃរបស់ពួកគេត្រូវបានឆ្លុះបញ្ចាំងតាមតម្លៃទីផ្សារ ឬតម្លៃបច្ចុប្បន្ន។ ការកែតម្រូវត្រូវបានធ្វើឡើងតាមកាលៈទេសៈ និងតាមតម្រូវការនៃស្តង់ដាគណនេយ្យ។

### ៥. ការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

- ការវាស់វែងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានដូចជា របាយការណ៍តុល្យការ (Balance Sheet) របាយការណ៍លទ្ធផល (Income Statement) និងរបាយការណ៍លំហូរសាច់ប្រាក់(Cash Flow Statement)។ ការបង្ហាញនេះត្រូវតែឆ្លុះបញ្ចាំងពីការវាយតម្លៃ និងការវាស់វែងដែលបានធ្វើឡើងតាមស្តង់ដាគណនេយ្យ។

សរុបមក ការវាស់វែងនៅក្នុង CIAS គឺជាដំណើរការសំខាន់ដែលធានាថាការរាយការណ៍ហិរញ្ញវត្ថុគឺត្រឹមត្រូវ និងឆ្លុះបញ្ចាំងពីស្ថានភាពហិរញ្ញវត្ថុពិតប្រាកដនៃក្រុមហ៊ុន។

## គ.ការលែងទទួលស្គាល់

ការលែងទទួលស្គាល់ (Derecognition) គឺជាដំណើរការមួយដែលក្រុមហ៊ុនលែងរួមបញ្ចូលនូវទ្រព្យសកម្ម ឬបំណុលរបស់ខ្លួន។ ខាងក្រោមនេះជាចំណុចសំខាន់នៃការលែងទទួលស្គាល់នៅក្នុង CIAS៖

### ១. ការលែងទទួលស្គាល់ទ្រព្យសកម្ម

- ការលក់ទ្រព្យសកម្ម គឺនៅពេលដែលទ្រព្យសកម្មត្រូវបានលក់ ក្រុមហ៊ុនត្រូវលែងទទួលស្គាល់ទ្រព្យសកម្មនោះពីសមតុល្យ[10]។
- ការបញ្ចប់កិច្ចសន្យា នៅពេលដែលកិច្ចសន្យាដែលទាក់ទងនឹងទ្រព្យសកម្មត្រូវបានបញ្ចប់ ក្រុមហ៊ុនត្រូវលែងទទួលស្គាល់ទ្រព្យសកម្មនោះ។
- ការបាត់បង់ការគ្រប់គ្រង នៅពេលដែលក្រុមហ៊ុនបាត់បង់នូវការគ្រប់គ្រងលើទ្រព្យសកម្ម ដូចនេះទ្រព្យសកម្មនោះត្រូវបានលែងទទួលស្គាល់ទៀតហើយ។

### ២. ការលែងទទួលស្គាល់បំណុល

[10] និយ័តករគណនេយ្យ និងសវនកម្ម.(2015,December 16). ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា. Retrieved from https://www.acar.gov.kh (Accessed 07.04.25)

- ការសងបំណុល គឺនៅពេលដែលក្រុមហ៊ុនសងបំណុលរួច ឬបំណុលត្រូវបានលុបចោល នោះត្រូវលែងទទួលស្គាល់។

### ៣. ការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

- ការលែងទទួលស្គាល់ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានដូចជា របាយការណ៍តុល្យការ (Balance Sheet) របាយការណ៍លទ្ធផល (Income Statement)។ ការបង្ហាញនេះត្រូវតែឆ្លុះបញ្ចាំងពីការលែងទទួលស្គាល់ និងផលប៉ះពាល់របស់វាលើស្ថានភាពហិរញ្ញវត្ថុនៃក្រុមហ៊ុន។

### ឃ.ការលាតត្រដាង

ការលាតត្រដាង (Disclosure) គឺជាការផ្តល់ព័ត៌មានច្បាស់លាស់ និងពេញលេញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន ដើម្បីធានាថាអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុមានការយល់ដឹងពេញលេញ និងអាចធ្វើការសម្រេចចិត្តបានត្រឹមត្រូវ[11]។ ខាងក្រោមនេះគឺជាចំណុចមួយចំនួននៃការលាតត្រដាងនៅក្នុង CIAS៖

- ការលាតត្រដាងអំពីគោលនយោបាយគណនេយ្យ ដោយក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានអំពីគោលនយោបាយគណនេយ្យដែលបានអនុវត្តរួមមាន វិធីសាស្ត្រវាស់វែង ការកំណត់តម្លៃទ្រព្យសកម្ម និងបំណុល ការកត់ត្រាប្រាក់ចំណូល និងការចំណាយ។
- ការលាតត្រដាងអំពីការធ្វើវិលស់ និងការសន្មត់ គឺក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានអំពីការធ្វើវិលស់ និងការសន្មត់ដែលបានធ្វើឡើងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ រួមមានការធ្វើវិលស់នៃអាយុកាលរបស់ទ្រព្យសកម្ម ការសន្មត់នៃអត្រាវិលស់ និងការធ្វើវិលស់លើការទូទាត់បំណុល។
- ការលាតត្រដាងអំពីទ្រព្យសកម្ម និងបំណុល គឺក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានលម្អិតអំពីទ្រព្យសកម្ម និងបំណុល រួមមានការចំណាយលើទ្រព្យសកម្ម ការប្រាក់លើបំណុល និងការទូទាត់បំណុល។
- ការលាតត្រដាងអំពីប្រាក់ចំណូល និងការចំណាយ គឺក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានអំពីប្រាក់ចំណូល និងការចំណាយ រួមមានប្រភពនៃប្រាក់ចំណូល ការចំណាយលើការប្រតិបត្តិការ និងការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍។
- ការលាតត្រដាងអំពីហានិភ័យ និងការគ្រប់គ្រងហានិភ័យ គឺក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានអំពីហានិភ័យផ្សេងៗ និងការគ្រប់គ្រងហានិភ័យ ដែលរួមមាន ហានិភ័យទីផ្សារ ហានិភ័យឥណទាន និងហានិភ័យប្រតិបត្តិការ។
- ការលាតត្រដាងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមាន របាយការណ៍តុល្យការ (Balance Sheet) របាយការណ៍ចំណូល (Income Statement) របាយការណ៍លំហូរសាច់ប្រាក់ (Cash Flow Statement) និងការកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (Notes to Financial Statements) ។

## ២.៣ សារៈសំខាន់ និងផលប៉ះពាល់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

[11] និយ័តករគណនេយ្យ និងសវនកម្ម. (2015, December 16). *ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា.* Retrieved from https://www.acar.gov.kh (Accessed 07.04.25)

ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា មានសារៈសំខាន់យ៉ាងខ្លាំងចំពោះប្រតិបត្តិការអាជីវកម្មដោយផ្តល់នូវការលើកស្ទួយដល់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលត្រឹមត្រូវ ច្បាស់លាស់ និងមានប្រសិទ្ធភាព[12]។ រួមមាន៖

- ការពង្រឹងភាពច្បាស់លាស់នៃព័ត៌មានហិរញ្ញវត្ថុ វាអាចជួយធានាថាព័ត៌មានហិរញ្ញវត្ថុដែលបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការនៅក្នុងអាជីវកម្មមានភាពត្រឹមត្រូវ និងច្បាស់លាស់។ វាអាចជួយពង្រឹងទំនុកចិត្តពីភាគីផ្ទាល់និងអតិថិជនដែលទទួលបានព័ត៌មានហិរញ្ញវត្ថុដែលអាចធាប់ត្រួតពិនិត្យបាន និងមានការពិចារណាទៅតាមគោលការណ៍ស្តង់ដា។
- ការអភិវឌ្ឍន៍សន្តិសុខ និងភាពទំនាក់ទំនងជាមួយភាគីផ្សេងៗ អាចជួយបង្កើនសន្តិសុខជាមួយភាគីទាំងអស់ (ដូចជា អតិថិជន អ្នកទិញ ធនាគារជាដើម) ពីព្រោះវាផ្តល់ជូននូវការបង្ហាញព័ត៌មានដែលមានប្រសិទ្ធភាព និងត្រឹមត្រូវ។ អាជីវកម្មដែលអនុវត្តស្តង់ដានេះអាចទទួលបានការទុកចិត្តច្រើនជាងក្នុងការប្រកួតប្រជែងលើទីផ្សារ។
- ជួយកែលម្អប្រព័ន្ធគណនេយ្យក្នុងអាជីវកម្ម វាបានជួយបង្ហាញពីវិធីសាស្ត្របានត្រឹមត្រូវក្នុងការបង្ហាញព័ត៌មានហិរញ្ញវត្ថុ និងការកំណត់សកម្មភាពហិរញ្ញវត្ថុ ហើយវាជួយធ្វើឱ្យអាជីវកម្មមានទិន្នន័យប្រកបដោយប្រសិទ្ធភាពសម្រាប់ការត្រួតពិនិត្យ និងគ្រប់គ្រងធនធានសេដ្ឋកិច្ចក្នុងការប្រតិបត្តិការនានា។
- ការកែលម្អសមត្ថភាពប្រកួតប្រជែង ការអនុវត្ត CIAS អាចជួយពង្រឹងសមត្ថភាពនៃការប្រកួតប្រជែង និងផ្តល់ជូនឱកាសនៃការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ និងកំណត់ការវិនិយោគនានា។
- ការអភិវឌ្ឍន៍វិធីសាស្ត្រទំនាក់ទំនងថ្មីៗ ជួយអាជីវកម្មក្នុងការអភិវឌ្ឍន៍ការទំនាក់ទំនងថ្មីៗ ជាមួយនឹងភាគីផ្សេងៗ និងធនាគារដោយមានព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុដែលត្រឹមត្រូវ និងត្រូវបានទទួលស្គាល់នៅលើទីផ្សារអន្តរជាតិ។
- ការផ្តល់ឱកាសសម្រាប់ការវិនិយោគ ផ្តល់ភាពច្បាស់លាស់នៅក្នុងការបង្ហាញព័ត៌មានហិរញ្ញវត្ថុ ដែលអាចជួយអ្នកវិនិយោគទទួលបានការពិចារណាផ្នែកហិរញ្ញវត្ថុ និងការចុះជួបគ្នាជាមួយអាជីវកម្ម ដែលបង្កើតនូវឱកាសក្នុងការវិនិយោគបានយ៉ាងមានប្រសិទ្ធភាព។
- ការកំណត់គោលនយោបាយគណនេយ្យត្រឹមត្រូវ ដោយបានជួយអាជីវកម្មកំណត់គោលនយោបាយគណនេយ្យដែលមានតុល្យភាព និងសុវត្ថិភាព។ វាពង្រឹងការប្រើប្រាស់នូវគោលការណ៍ និងវិធីសាស្ត្រអន្តរជាតិដែលអាចបញ្ជាក់តាមការផ្គត់ផ្គង់សេវាកម្មដោយមានគុណភាពល្អឥតខ្ចោះ។
- ជួយបង្កើតសមភាពក្នុងការប្រកួតប្រជែងជាមួយអាជីវកម្មអន្តរជាតិ ដោយការអនុវត្ត CIAS អាជីវកម្មក្នុងស្រុកអាចប្រើស្តង់ដាដែលស្មើនឹងអាជីវកម្មអន្តរជាតិធំៗ។ វាជាជំហានដ៏សំខាន់សម្រាប់ការចូលរួមប្រកួតប្រជែងយ៉ាងស្មើភាព និងបើកទ្វារទៅកាន់ទីផ្សារក្រៅប្រទេស។
- ជួយសម្រួលការបង្កើតរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនិងស្ថាប័នជាន់ខ្ពស់ អាជីវកម្មអាចប្រើប្រាស់ទិន្នន័យហិរញ្ញវត្ថុដែលបានចងក្រងត្រឹមត្រូវតាម CIAS សម្រាប់ការធ្វើសេចក្តីសម្រេចយុទ្ធសាស្ត្រផ្លូវការជាប្រចាំ។
- ជួយបង្កើនភាពរឹងមាំលើការត្រួតពិនិត្យក្នុងអង្គភាព ការអនុវត្តស្តង់ដានេះជួយឱ្យមានការប្រព្រឹត្តទៅ

[12] ភ្នំពេញប៉ុស្តិ៍. (2020, October 26). *ហេតុអ្វីបានជាស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាមានសារៈសំខាន់?* Retrieved from https://m.postkhmer.com (Accessed 07.04.25)

នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (Internal control system) ដែលអាចទប់ស្កាត់ហានិភ័យ និងកាត់បន្ថយការបាត់បង់ធនធាន។

- ជួយបង្កើតស្ថិរភាពក្នុងការរៀបចំផែនការហិរញ្ញវត្ថុយ៉ាងរហ័ស និងប្រសើរ ជាមួយព័ត៌មានជាក់ស្តែង និងស្របតាមស្តង់ដា អាជីវកម្មអាចរៀបចំផែនការហិរញ្ញវត្ថុយ៉ាងត្រឹមត្រូវ ដូចជា ផែនការចំណូលចំណាយ ការរំពឹងលទ្ធផល និងការគ្រប់គ្រងហានិភ័យ។

- ជួយបង្កើតភាពជឿជាក់សម្រាប់ការទទួលបានប្រាក់កម្ចី ប្រាក់កម្ចីពីធនាគារ និងមជ្ឈមណ្ឌលហិរញ្ញវត្ថុជាច្រើន ត្រូវការព័ត៌មានហិរញ្ញវត្ថុដែលអាចជឿទុកចិត្តបាន។

- ជួយឱ្យមានសមភាពក្នុងការប្រកាសពន្ធ និងបំពេញកាតព្វកិច្ចច្បាប់ ព័ត៌មានហិរញ្ញវត្ថុត្រឹមត្រូវពិតជាមានសារៈសំខាន់សម្រាប់ការគណនាពន្ធលើប្រាក់ចំណេញ និងកិច្ចការផ្សេងៗដែលទាក់ទងនឹងច្បាប់។

- ជាជម្រើសសំខាន់សម្រាប់អាជីវកម្មចង់ចុះបញ្ជីលើទីផ្សារហ៊ុន (IPO) អាជីវកម្មដែលមានគម្រោងចង់ចូលផ្សារហ៊ុនត្រូវតែបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលត្រឹមត្រូវ។ CIAS ជួយក្នុងបំពេញលក្ខណៈនោះ និងពង្រឹងឱកាសទទួលបានការអនុម័ត។

- ជួយបង្កើតសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុ ប្រកបដោយចីរភាព ដោយមាននូវប្រព័ន្ធស្តង់ដាដែលមានគុណភាពអាជីវកម្មអាចគ្រប់គ្រងហិរញ្ញវត្ថុដោយមានចក្ខុវិស័យវែង និងមានស្ថិរភាពនាពេលអនាគត។

សរុបមក CIAS មានសារៈសំខាន់ចំពោះប្រតិបត្តិការអាជីវកម្មនៅក្នុងការពង្រឹងភាពត្រឹមត្រូវ វាអាចជួយបង្កើតឱកាសថ្មីៗសម្រាប់អាជីវកម្មក្នុងការកែលម្អប្រព័ន្ធគណនេយ្យ និងការពង្រឹងភាពទំនាក់ទំនងបានកាន់តែច្រើនជាមួយភាគីផ្សេងៗ។ នៅក្នុងការអនុវត្ត CIAS ធានាបានថាអាជីវកម្មមានទំនាក់ទំនងដែលប្រកបដោយប្រសិទ្ធភាព និងមានការចូលរួមប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិកាន់តែឆាប់រហ័ស។

បើទោះបីជាស្តង់ដានេះមានប្រសិទ្ធភាពយ៉ាងណាក៏ដោយ ក៏នៅតែមានផលប៉ះពាល់មួយចំនួនដែលអាចកើតមានកំឡុងពេលអនុវត្តផងដែរ ដូចជា៖

- ការកើនឡើងនៃចំណាយប្រតិបត្តិការ៖ ត្រូវប្តូរប្រព័ន្ធគណនេយ្យ និង Software ត្រូវជួលអ្នកជំនាញ និងអ្នកប្រឹក្សា បន្ថែមចំណាយក្នុងការបណ្តុះបណ្តាលបុគ្គលិក។

- ការខ្វះខាតធនធានមនុស្ស៖ អាជីវកម្មជាច្រើនគ្មានអ្នកជំនាញគ្រប់គ្រាន់ក្នុងការអនុវត្ត CIAS បានត្រឹមត្រូវ។

- ស្មុគស្មាញក្នុងការគ្រប់គ្រង៖ បង្កើតការលំបាកក្នុងការរៀបចំ និងរាយការណ៍ទិន្នន័យហិរញ្ញវត្ថុ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់។

- ហានិភ័យនៃកំហុស និងទណ្ឌកម្ម៖ ប្រសិនបើអាជីវកម្មអនុវត្តមិនត្រឹមត្រូវ អាចនាំទៅដល់ទណ្ឌកម្មច្បាប់ ឬបាត់បង់កិត្តិយស។

- ភាពមិនស្មើគ្នា៖ ក្រុមហ៊ុនធំៗអាចអនុវត្តបានយ៉ាងរលូន ខណៈក្រុមហ៊ុនតូចៗប្រឈមនឹងការលំបាកធ្ងន់ធ្ងរ បង្កើតភាពខ្វែងគ្នាផងដែរ។

# ជំពូកទី៣
# សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ នៅក្នុងស្ថាប័ននិយ័តករគណនេយ្យ និងសវនកម្ម

## ៣.១ ស្ថានភាពទូទៅរបស់និយ័តករគណនេយ្យ និងសវនកម្ម

### ៣.១.១ ប្រវត្តិរបស់និយ័តករគណនេយ្យ និងសវនកម្ម

កាលពីមុននិយ័តករគណនេយ្យ និងសវនកម្ម (ACAR) មានឈ្មោះថាក្រុមប្រឹក្សាជាតិគណនេយ្យ (National Accounting Council - NAC) គិតចាប់ពីថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០៣ ។ ហើយក្រោយមកត្រូវបានប្រែក្លាយឈ្មោះទៅជា និយ័តករគណនេយ្យ និងសវនកម្ម (Accounting and Auditing Regulator - ACAR) ចាប់ពីឆ្នាំ២០២១ រហូតមកដល់បច្ចុប្បន្ននេះ។ និយ័តករគណនេយ្យ និងសវនកម្ម ត្រូវបានអនុវត្តន៍មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ ដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្មដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២១ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យគណនេយ្យ និងសវនកម្ម។ និយ័តករគណនេយ្យ និងសវនកម្ម មានទីតាំងស្ថិតនៅផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។




និយ័តករគណនេយ្យ និងសវនកម្ម (ACAR) ត្រូវបានបង្កើតឡើងដោយស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ACAR បានបង្កើតឡើងដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងវិស័យគណនេយ្យ និងសវនកម្មក្នុងប្រទេសកម្ពុជា ហើយបានជំរុញឱ្យមានការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ (IFRS/IAS) និង

ស្តង់ដាសវនកម្មអន្តរជាតិ (ISA) ដើម្បីធានាឱ្យមានភាពត្រឹមត្រូវ និងច្បាស់លាស់នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ភារកិច្ចរបស់ ACAR រួមមាន៖

- ត្រួតពិនិត្យ និងអនុវត្តច្បាប់ ទាក់ទងនឹងគណនេយ្យ និងសវនកម្ម
- ចេញអាជ្ញាប័ណ្ណ និងវិញ្ញាបនបត្រ ចំពោះអ្នកជំនាញ និងក្រុមហ៊ុនសវនកម្ម
- បង្កើត និងអនុវត្តស្តង់ដាគណនេយ្យ ដើម្បីឱ្យស្របនឹងស្តង់ដាអន្តរជាតិ
- បង្កើនការយល់ដឹង អំពីគណនេយ្យ និងសវនកម្មចំពោះសាធារណជន និងវិស័យឯកជន
- សហការជាមួយអង្គភាពអន្តរជាតិ ដើម្បីលើកកម្ពស់វិស័យនេះនៅកម្ពុជា។

ការបង្កើត ACAR មានផលប្រយោជន៍ដល់សេដ្ឋកិច្ចដូចជា៖

- ការចាប់អារម្មណ៍វិនិយោគកម្ម ការមានប្រព័ន្ធគណនេយ្យប្រកបដោយតម្លាភាព និងអាចទុកចិត្តបាន ជួយជម្រុញឱ្យវិនិយោគិនអន្តរជាតិមានទំនុកចិត្តក្នុងការវិនិយោគនៅកម្ពុជា
- ការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច ដោយបានបង្កើននូវប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ស្ថាប័នរដ្ឋ និងឯកជន
- បង្កើនសមត្ថភាពប្រទេសកម្ពុជានៅលើវេទិកាសេដ្ឋកិច្ចអន្តរជាតិ ដោយសារតែការអនុវត្តស្តង់ដាដែលទទួលស្គាល់ជាសកល។

ACAR មិនត្រឹមតែជាអង្គភាពត្រួតពិនិត្យប៉ុណ្ណោះទេ ប៉ុន្តែគឺជាគ្រឹះដ៏សំខាន់មួយក្នុងការបង្កើតប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយតម្លាភាព សុចរិត និងគុណភាពខ្ពស់នៅក្នុងប្រទេសកម្ពុជា។ តួនាទីរបស់ ACAR នឹងបន្តអភិវឌ្ឍ និងជួយឱ្យកម្ពុជាបានឈានដល់វិស័យហិរញ្ញវត្ថុស៊ីវិល័យ និងអាចប្រកួតប្រជែងជាមួយប្រទេសផ្សេងៗទៀតក្នុងតំបន់ និងពិភពលោក។

ការបង្កើតនិយ័តករគណនេយ្យ និងសវនកម្ម (ACAR) នេះឡើង គឺដើម្បីធានាឱ្យមាននូវការគោរពទៅតាមស្តង់ដាអន្តរជាតិ និងការលាតត្រដាងទិន្នន័យហិរញ្ញវត្ថុឱ្យមានភាពត្រឹមត្រូវ ហើយវាជាជំហានសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងការវិនិយោគក្នុងប្រទេសកម្ពុជា។ ប្រព័ន្ធត្រួតពិនិត្យជាប្រចាំ និងស្តង់ដាទាំងក្នុងស្រុក និងអន្តរជាតិត្រូវបានបង្កើតឡើងដើម្បីធានាបាននូវភាពត្រឹមត្រូវ និងតម្លាភាពនៅក្នុងវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា។

សមាសភាពសមាជិកក្រុមប្រឹក្សាភិបាលតាមអាណត្តិនីមួយៗ ក្នុងមួយអាណត្តិមានរយៈពេល ៣ ឆ្នាំ ដែលមានដូចខាងក្រោម៖

- សមាសភាព១៣នាក់នៃអាណត្តិទី១ ចាប់ពីថ្ងៃ០៣/០៣/២០០៣ ដល់ថ្ងៃ០៣/០៣/២០០៦ ៖

| | | |
|---|---|---|
| ១- ឯកឧត្តម ងី តាយី អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | ជា ប្រធាន |
| ២- លោក គុយ លឹម | Price WaterHouse Coopers | ជាអនុប្រធាន |
| ៣- លោក យិនន៍ ត័យឈន់ | ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ | ជា សមាជិក |
| ៤- លោក ចាន់ សុធី | ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ | ជា សមាជិក |
| ៥- លោក ហេង វ៉ាន់ដា | ក្រសួងអប់រំយុវជន និងកីឡា | ជា សមាជិក |
| ៦- លោក អ៊ូ ចាន់តារា | ធនាគារជាតិនៃកម្ពុជា | ជា សមាជិក |

| | | |
|---|---|---|
| ៧- លោក កាំង តុងហ៊ាង | ធនាគារជាតិនៃកម្ពុជា | ជា សមាជិក |
| ៨- លោក ឈិន កុសល | ក្រសួងយុត្តិធម៌ | ជា សមាជិក |
| ៩- លោក ង៉ែត សូភិន | ក្រសួងពាណិជ្ជកម្ម | ជា សមាជិក |
| ១០- លោក ហាវ៉ាណស៊ីរិល័យ | សភាពាណិជ្ជកម្ម | ជា សមាជិក |
| ១១- អ្នកស្រី ជុង រ៉ានី | សភាពាណិជ្ជកម្ម | ជា សមាជិក |
| ១២- លោក មាស សក្តិសម | ក្រុមហ៊ុនម៉ូរីសុនកាក់និងអាសូស្បេរ | ជា សមាជិក |
| ១៣- លោក ង៉ែ ហ៊ុយ | KPMG | ជា សមាជិក |

- សមាសភាព១៣នាក់នៃអាណត្តិទី២ ចាប់ពីថ្ងៃ០៣/០៣/២០០៦ ដល់ ថ្ងៃ០៣/០៣/២០០៦ ៖

| | | |
|---|---|---|
| ១. ឯក ឧត្តម ងី តាយី | ក្រសួងហិរញ្ញវត្ថុ | ជា ប្រធាន |
| ២. លោក ហេង វ៉ាន់ដា | សភាពាណិជ្ជកម្ម | ជា សមាជិក |
| ៣. លោក ឃិនន៍ ត័យឈន់ | ក្រសួងហិរញ្ញវត្ថុ | ជា សមាជិក |
| ៤. លោក តាំង តុងហ៊ាង | ធនាគារជាតិ | ជា សមាជិក |
| ៥. លោក អ៊ូ ចាន់ភាព | ធនាគារជាតិ | ជា សមាជិក |
| ៦. លោក រស់ សុខុម | ក.ហ.វ | ជា សមាជិក |
| ៧. លោក មាស សក្តិសម | KICPAA | ជា សមាជិក |
| ៨. លោក ង៉ែ ហយ | KPMG | ជា សមាជិក |
| ៩. លោក ខូយ គឹមលេង | PWC | ជា សមាជិក |
| ១០. លោក កាំង សុជាតិ | ក.ព.ណ | ជា សមាជិក |
| ១១. លោក ហួត ច័ន្ទនិមល | សភាពាណិជ្ជកម្ម | ជា សមាជិក |
| ១២. លោក សេង សារ៉ែន | ក្រសួងអប់រំ | ជា សមាជិក |
| ១៣. លោក ឈិន កុសល | ក្រសួងយុត្តិធម៌ | ជា សមាជិក |

- សមាសភាព១៣នាក់នៃអាណត្តិទី៣ ចាប់ពីថ្ងៃ០១/០៥/២០០៩ ដល់ ថ្ងៃ៣០/០៤/២០១១ ៖

| | | |
|---|---|---|
| ១. ឯកឧត្តម ងី តាយី | ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ | ជា ប្រធាន |
| ២. លោក ង៉ែ ហ៊ុយ | KPMG | ជា អនុប្រធាន |
| ៣. លោក ឈុន សម្បត្តិ | គណៈកម្មាធិការមូលបត្រកម្ពុជា | ជា សមាជិក |
| ៤. លោក អេង រតនា | ពន្ធដារ | ជា សមាជិក |
| ៥. លោក ឈិន កុសល | ក្រសួងយុត្តិធម៌ | ជា សមាជិក |
| ៦. លោក អ៊ូ ចាន់តារា | ធនាគារជាតិនៃកម្ពុជា | ជា សមាជិក |
| ៧. លោក រ័ត្ន សុវណ្ណនរៈ | ធនាគារជាតិនៃកម្ពុជា | ជា សមាជិក |
| ៨. លោក ហេង វ៉ាន់ដា | សភាពាណិជ្ជកម្មនៃកម្ពុជា | ជា សមាជិក |
| ៩. លោក ស្រី ហ៊ួត ច័ន្ទនិមល | សភាពាណិជ្ជកម្មនៃកម្ពុជា | ជា សមាជិក |
| ១០. លោក មាស សក្តិសម | KICPAA | ជា សមាជិក |

| | | |
|---|---|---|
| ១១. លោក ខូយ គឹមឡេង | PWC | ជា សមាជិក |
| ១២.លោក កាំង សុជាតិ | ក្រសួងពាណិជ្ជកម្មនៃកម្ពុជា | ជា សមាជិក |
| ១៣. លោក សេង សារ៉ន | ក្រសួងអប់រំ យុវជន និងកីឡា | ជា សមាជិក |
| ១៤. លោក ប៊ូ ថារិន | ក្រុមប្រឹក្សាជាតិគណនេយ្យ | លេខាធិការអចិន្ត្រៃយ៍ |

- សមាសភាព១៣នាក់នៃអាណត្តិទី៤ ចាប់ពីថ្ងៃ២៥/០៥/២០១២ដល់ ថ្ងៃ២៥/០៥/២០១១ ៖

| | | |
|---|---|---|
| ១.ឯកឧត្តម ងី តាយី | ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ | ជា ប្រធាន |
| ២.លោក ហេង វ៉ាន់ដា | សភាពាណិជ្ជកម្ម | ជា អនុប្រធាន |
| ៣. លោក ឈុន សម្បត្តិ | គណៈកម្មាធិការមូលបត្រកម្ពុជា | ជា សមាជិក |
| ៤. លោក ង៉ែ ហ៊ុយ | KPMG | ជា សមាជិក |
| ៥.លោក គុយ លីម | PWC | ជា សមាជិក |
| ៦. លោក ខូយគីមឡេង | PWC | ជា សមាជិក |
| ៧. លោក រ័ត្ន សុវណ្ណនរៈ | ធនាគារជាតិនៃកម្ពុជា | ជា សមាជិក |
| ៨.លោក អ៊ូ ចាន់តារា | ធនាគារជាតិនៃកម្ពុជា | ជា សមាជិក |
| ៩. លោក ស្រី ហ៊ួត ច័ន្ទនិមល | សភាពាណិជ្ជកម្មនៃកម្ពុជា | ជា សមាជិក |
| ១០.លោក កាំង សុជាតិ | ក្រសួងពាណិជ្ជកម្មនៃកម្ពុជា | ជា សមាជិក |
| ១១. លោក សេង សារ៉ន | ក្រសួងអប់រំ យុវជន និង កីឡា | ជា សមាជិក |
| ១២. លោក សៀង ស៊ីថា | ពន្ធដារ | ជា សមាជិក |
| ១៣. លោក ចេង គីមហ៊ាង | ក្រសួងយុត្តិធម៌ | ជា សមាជិក |

- សមាសភាព១៣នាក់នៃអាណត្តិទី៥ ចាប់ពីថ្ងៃ០៥/០១/២០១៦ដល់ ថ្ងៃ០៥/០១/២០១៩ ៖

| | | |
|---|---|---|
| ១.ឯកឧត្តម ងី តាយី | ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ | ជា ប្រធាន |
| ២.លោក ហេង វ៉ាន់ដា | សភាពាណិជ្ជកម្ម | ជា អនុប្រធាន |
| ៣. លោក ឈុន សម្បត្តិ | គណៈកម្មាធិការមូលបត្រកម្ពុជា | ជា សមាជិក |
| ៤. ឯកឧត្តម ប៊ី ហ៊ត់ | ក្រសួងពាណិជ្ជកម្ម | ជា សមាជិក |
| ៥. ឯកឧត្តម ឧកញ៉ា ស៊ិន សុខណា | សភាពាណិជ្ជកម្មកម្ពុជា | ជា សមាជិក |
| ៦.លោក សៀង ស៊ីថា | ពន្ធដារ | ជា សមាជិក |
| ៧.លោក លាវ ពិសិដ្ឋ | ក្រសួងយុត្តិធម៌ | ជា សមាជិក |
| ៨.លោក រ័ត្ន សុវណ្ណនរៈ | ធនាគារជាតិនៃកម្ពុជា | ជា សមាជិក |
| ៩.លោក អ៊ូ ចាន់តារា | ធនាគារជាតិនៃកម្ពុជា | ជា សមាជិក |
| ១០. លោក សុខ សូហេម៉ា | ក្រសួងអប់រំ យុវជន និង កីឡា | ជា សមាជិក |
| ១១.លោក ខូយ គីមឡេង | វ.គ.ស.ក | ជា សមាជិក |
| ១២.លោក គុយ លីម | វ.គ.ស.ក | ជា សមាជិក |
| ១៣.លោក ង៉ែ ហ៊ុយ | វ.គ.ស.ក | ជា សមាជិក |

### ៣.១.២ ទស្សនវិស័យ បេសកកម្ម និងគោលដៅរបស់និយ័តករគណនេយ្យ និងសវនកម្ម

**- ទស្សនវិស័យ**

និយ័តករគណនេយ្យ និងសវនកម្ម (ACAR) នឹងក្លាយជាស្ថាប័ននិយ័តករដែលមានសមត្ថភាពខ្ពស់ និងគុណតម្លៃវិជ្ជាជីវៈរឹងមាំ ស្របតាមស្តង់ដាអន្តរជាតិ និងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងវិជ្ជាជីវៈ។ ACAR មានបំណងបង្កើតប្រព័ន្ធគ្រប់គ្រងវិស័យគណនេយ្យ និងសវនកម្មដែលមានប្រសិទ្ធភាព ប្រកបដោយភាពតម្លាភាព គណនេយ្យភាព និងនិរន្តភាព ដើម្បីធ្វើឱ្យប្រព័ន្ធនេះមានសុវត្ថិភាព ពង្រឹងភាពជឿជាក់របស់សាធារណជន និងបំពេញតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។ ACAR ប្តេជ្ញាថានឹងក្លាយជាគ្រឹះដ៏សំខាន់មួយសម្រាប់ការគាំទ្រនិងដឹកនាំការអភិវឌ្ឍវិស័យគណនេយ្យ និងសវនកម្មជាតិ ដោយធ្វើការជាមួយរាជរដ្ឋាភិបាល វិស័យឯកជន ស្ថាប័នការសិក្សា សហគមន៍អាជីព និងសហគមន៍អន្តរជាតិ។ ស្ថាប័ននេះនឹងចូលរួមយ៉ាងសកម្មក្នុងការធានានូវភាពសមរម្យ និងគុណភាពខ្ពស់នៃសេវាផ្នែកគណនេយ្យ និងសវនកម្ម ដែលអាចជួយទ្រទ្រង់ការធ្វើសេចក្តីសម្រេចផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងប្រកបដោយចំណេះដឹង និងការទទួលខុសត្រូវ។ មិនតែប៉ុណ្ណោះ ACAR ក៏នឹងជះឥទ្ធិពលវិជ្ជាជីវៈដើម្បីជម្រុញការចូលរួមរបស់វិជ្ជាជីវៈគណនេយ្យ និងសវនកម្មក្នុងវិស័យសាធារណៈ និងឯកជន ដើម្បីអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុជាតិឱ្យកាន់តែរឹងមាំ។ វាមានតួនាទីសំខាន់ក្នុងការជម្រុញការប្រើប្រាស់ស្តង់ដាអន្តរជាតិ ដូចជា IFRS/IAS និង ISA នៅកម្ពុជា តាមរយៈការផ្តល់ច្បាប់ អាជ្ញាបណ្ណ ការត្រួតពិនិត្យ និងការអប់រំបន្តដល់អ្នកប្រកបអាជីពក្នុងវិស័យនេះ។

ដោយសារតែតួនាទីដ៏សំខាន់នេះ ACAR នឹងក្លាយជាដៃគូរបស់រដ្ឋ និងវិស័យឯកជន ក្នុងការបង្កើតប្រព័ន្ធសេដ្ឋកិច្ចដែលមានភាពធាប់ប្រតិបត្តិ ភាពជឿជាក់ និងគាំទ្របានចំពោះការអភិវឌ្ឍយ៉ាងចីរភាពទាំងសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

**- បេសកកម្ម**

និយ័តករគណនេយ្យ និងសវនកម្ម (ACAR) បានបំពេញមុខងារជាសេនាធិការសម្រាប់អគ្គនាយកដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ.ស.ហ.) ក្នុងការគ្រប់គ្រង និងអភិវឌ្ឍវិស័យគណនេយ្យ និងសវនកម្ម។ មុខងារនេះត្រូវបានអនុវត្តតាមរយៈការចេញផ្សាយ និងអនុវត្តន៍នូវបទប្បញ្ញត្តិ វិធានការ គោលនយោបាយ និងស្តង់ដាផ្លូវការដែលមានគោលបំណងសំខាន់ ក្នុងការកំណត់ស្តង់ដារម្នាក់ប្រកបអាជីព និងការអនុវត្តវិជ្ជាជីវៈដោយមានស្មារតីទំនួលខុសត្រូវ និងគុណតម្លៃខ្ពស់។ (ACAR) ប្តេជ្ញាជំរុញការអនុវត្តច្បាប់ស្តង់ដាគណនេយ្យ (IFRS/IAS) និងស្តង់ដាសវនកម្ម (ISA) ដែលទាន់សម័យ និងស្របតាមអន្តរជាតិ ដើម្បីធានាបាននូវភាពស្មោះត្រង់ត្រឹមត្រូវ និងភាពជឿជាក់នៅក្នុងការរាយការណ៍ហិរញ្ញវត្ថុ។ ការងារនេះនឹងជួយបង្កើនសេចក្តីទុកចិត្តរបស់អ្នកមានចំណាប់អារម្មណ៍ រួមទាំងអាជ្ញាធរ រដ្ឋាភិបាល វិនិយោគិន ស្ថាប័នហិរញ្ញវត្ថុ និងសាធារណជន។ (ACAR) ក៏មានតួនាទីសំខាន់ក្នុងការធានា និងលើកកម្ពស់គុណភាពវិជ្ជាជីវៈ របស់អ្នកប្រកបអាជីពតាមរយៈ៖

- ការផ្តល់អាជ្ញាបណ្ណ និងការទទួលស្គាល់វិជ្ជាជីវៈ
- ការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តន៍វិជ្ជាជីវៈ
- ការរៀបចំ និងសម្របសម្រួលកម្មវិធីបណ្តុះបណ្តាល និងបន្តការសិក្សាវិជ្ជាជីវៈ
- ការបង្កើតប្រព័ន្ធចុះបញ្ជីស្តង់ដា និងធនាគារ អ្នកជំនាញក្នុងវិស័យនេះ។

ន.គ.ស. នឹងបន្តជួសជុល និងពង្រឹងប្រព័ន្ធគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មឱ្យមានប្រសិទ្ធភាព និងភាពប្រសើរឡើងជាបន្តបន្ទាប់ ដើម្បីជាសោភ័ណ្ឌភាពសម្រាប់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ប្រកបដោយភាពត្រឹមត្រូវ និងចីរភាព។

### ៣.១.៣ រចនាសម្ព័ន្ធ និងតួនាទីរបស់និយ័តករគណនេយ្យ និងសវនកម្ម




រចនាសម្ព័ន្ធនៃការគ្រប់គ្រង:

- ឯកឧត្តម ប៊ូ ថារិន អគ្គនាយក
- លោក ជា ចាន់ថា អគ្គនាយករង
- លោក ជេន ផាត អគ្គនាយករង
- លោកស្រី នាន បូនី អគ្គនាយករង

ដោយខាងក្រោមនេះ ជានាយកដ្ឋាននៃនិយ័តករគណនេយ្យនិងសវនកម្ម៖

១.នាយកដ្ឋានកិច្ចការទូទៅ ជាសេនាធិការឱ្យ ន.គ.ស. លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងបូកសរុបផែនការសកម្មភាពរួម របស់ ន.គ.ស.

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានកិច្ចការទូទៅ
- រៀបចំថវិកាសម្រាប់កិច្ចដំណើរការរបស់ ន.គ.ស.
- គ្រប់គ្រងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់ ន.គ.ស.
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្សរបស់ ន.គ.ស.
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម ន.គ.ស. និងរៀបចំបញ្ជីសារពើភ័ណ្ឌ
- រៀបចំដាក់ឱ្យដំណើរការ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងការផ្សព្វផ្សាយរបស់ ន.គ.ស
- ទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន
- ផ្សព្វផ្សាយជាសាធារណៈពីកិច្ចដំណើរការនិងវឌ្ឍនភាពរបស់ ន.គ.ស.
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ ន.គ.ស. ។

២.នាយកដ្ឋានបច្ចេកទេស ជាសេនាធិការឱ្យ ន.គ.ស. លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានបច្ចេកទេស
- សិក្សាស្រាវជ្រាវ និងរៀបចំនូវស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ក្រមសីលធម៌វិជ្ជាជីវៈ និងស្តង់ដាពាក់ព័ន្ធ
- ពន្យល់ និងបកស្រាយលើទិដ្ឋភាពបច្ចេកទេសនៃស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ក្រមសីលធម៌វិជ្ជាជីវៈ និងស្តង់ដាពាក់ព័ន្ធ
- ពិនិត្យឡើងវិញទៅលើការអនុវត្តស្តង់ដា និងកំណត់បញ្ហាប្រឈម ទាំងទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពបទប្បញ្ញត្តិ ព្រមទាំងស្នើឡើងនូវដំណោះស្រាយ
- សហការ និងចូលរួមជាមួយស្ថាប័នតំបន់ និងអន្តរជាតិ ក្នុងការរៀបចំធ្វើបច្ចុប្បន្នភាព អភិវឌ្ឍស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ក្រមសីលធម៌វិជ្ជាជីវៈ និងស្តង់ដាពាក់ព័ន្ធ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ ន.គ.ស. ។

៣.នាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ជាសេនាធិការឱ្យ ន.គ.ស. លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- ពិនិត្យ ផ្តល់យោបល់លើសំណើសុំអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- ពិនិត្យនិងផ្តល់យោបល់លើវិធានការចំពោះអំពើល្មើសទៅនឹងបទប្បញ្ញត្តិស្តីពីការផ្តល់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិចាំបាច់នានា ទាក់ទងនឹងការផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- ត្រួតពិនិត្យគុណភាពសេវាគណនេយ្យនិងសវនកម្ម
- រៀបចំ និងគ្រប់គ្រងទិន្នន័យក្រុមហ៊ុនគណនេយ្យ និងក្រុមហ៊ុនសវនកម្ម
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា

- រៀបចំដាក់ឱ្យដំណើរការ និងគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- ចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយក ន.គ.ស. ។

៤.នាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាព ជាសេនាធិការឱ្យ ន.គ.ស.លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាព
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិចាំបាច់នានា
- ពិនិត្យ និងផ្តល់យោបល់លើវិធានការពង្រឹងការអនុវត្តច្បាប់
- រៀបចំ និងគ្រប់គ្រងទិន្នន័យអំពីសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- ត្រួតពិនិត្យអនុលោមភាពតាមច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាពាក់ព័ន្ធ
- គ្រប់គ្រង ត្រួតពិនិត្យទាំងលើឯកសារ និងដល់ទីកន្លែង និងវាយតម្លៃលើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស និងអង្គភាពដែលមិនស្វែងរកប្រាក់ចំណេញ
- ចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- រៀបចំការបណ្តុះបណ្តាល និងការផ្សព្វផ្សាយច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាពាក់ព័ន្ធ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ ន.គ.ស. ។

## ៣.២ ទស្សនៈរបស់និយ័តករគណនេយ្យ និងសវនកម្មទៅលើ (CIAS-16)

### ៣.២.១ វិសាលភាពនៃការអនុវត្ត

វិសាលភាពនៃការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ (Cambodian International Accounting Standard - 16) គឺត្រូវបានអនុវត្តទៅលើអាជីវកម្ម និងអង្គភាពហិរញ្ញវត្ថុដែលមានទ្រព្យសកម្មសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មរបស់ពួកគេ។

អ្នកដែលត្រូវអនុវត្ត CIAS-16៖

- ក្រុមហ៊ុនដែលរៀបចំ របាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដាគណនេយ្យអន្តរជាតិ
- សហគ្រាសដែលមាន ទ្រព្យសកម្ម ដូចជា រោងចក្រ, ម៉ាស៊ីន, ឃ្លាំង, ឧបករណ៍, អគារ,យានជំនិះ
- ក្រុមហ៊ុនធំៗ និងក្រុមហ៊ុនចុះហត្ថលេខាលើបញ្ជីលិខិតបត្រ
- អាជីវកម្មអន្តរជាតិ និងក្នុងស្រុកដែលប្រតិបត្តិការជាលក្ខណៈពាណិជ្ជកម្ម
- អង្គភាពរដ្ឋ ឬអង្គការ ដែលប្រើប្រាស់ទ្រព្យសកម្ម សម្រាប់សេវាកម្ម។

CIAS-16 អាចអនុវត្តលើវិស័យអាជីវកម្មផ្សេងៗ ដូចជា៖

- វិស័យផលិតកម្ម (Manufacturing Sector) ក្រុមហ៊ុនផលិតដែលរួមមាន រោងចក្រ ម៉ាស៊ីនឧបករណ៍ផលិតកម្ម ( ឧ.រោងចក្រផលិតសំលៀកបំពាក់, គ្រឿងអេឡិចត្រូនិច, សម្ភារៈសំណង់ )
- វិស័យសំណង់ និងអចលនទ្រព្យ (Construction & Real Estate) ក្រុមហ៊ុនសំណង់ដែលមានឧបករណ៍, អគារ, ដីធ្លី ( ឧ.ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ,ក្រុមហ៊ុនសំណង់អគារពាណិជ្ជកម្មជាដើម)

- វិស័យដឹកជញ្ជូន (Transport & Logistics) ក្រុមហ៊ុនដែលមាន យានជំនិះ, ឃ្លាំង, ឧបករណ៍ដឹកជញ្ជូន (ឧ.ក្រុមហ៊ុនកុងតឺន័រ, ក្រុមហ៊ុនបន្ទុក, ក្រុមហ៊ុនដឹកជញ្ជូនអាកាស)
- វិស័យសេវាកម្ម និងបណ្តាញអគ្គិសនី (Utilities & Services) ក្រុមហ៊ុនផ្គត់ផ្គង់ អគ្គិសនី, ទឹកស្អាត ប្រព័ន្ធទូរគមនាគមន៍ (ឧ.ក្រុមហ៊ុនបំបែកអគ្គិសនី, ក្រុមហ៊ុនទឹកស្អាត)
- វិស័យសណ្ឋាគារ និងទេសចរណ៍ (Hospitality & Tourism) សណ្ឋាគារ និងក្រុមហ៊ុនដែលមាន អគារសម្ភារៈធុនធំ (ឧ.សណ្ឋាគារប្រាក់ផ្កាយ 4 និង 5, ក្រុមហ៊ុនដំណើរកំសាន្ត)។

អ្នកដែលមិនអនុវត្ត CIAS-16៖

- ទ្រព្យសកម្មដែលគ្រប់គ្រងដោយស្តង់ដាគណនេយ្យផ្សេងទៀត (ឧ.CIAS-40 ទ្រព្យវិនិយោគ)
- ទ្រព្យសកម្មដែលត្រូវបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់
- ទ្រព្យសកម្មជីវសាស្ត្រ ដែលទាក់ទងទៅនឹងសកម្មភាពកសិកម្ម
- ទ្រព្យធម្មជាតិ ដែលមិនអាចវាយតម្លៃបានយ៉ាងច្បាស់លាស់។

CIAS-16 មានឥទ្ធិពលធំលើប្រព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្តល់នូវវិធានការសម្រាប់ការប្រើប្រាស់ទ្រព្យសកម្ម ដែលអាចជៀសវាងការបាត់បង់ហិរញ្ញវត្ថុ ដូចជា៖

- ការបង្កើនប្រសិទ្ធភាពធនធាន ក្នុងការប្រើប្រាស់ CIAS-16 ធ្វើឱ្យសហគ្រាសអាចវាយតម្លៃ និងគ្រប់គ្រងទ្រព្យសកម្មបានល្អជាងមុន
- ការរក្សាភាពត្រឹមត្រូវនៃការរាយការណ៍ហិរញ្ញវត្ថុ ធានាបានថាទ្រព្យសកម្មត្រូវបានគណនាដោយត្រឹមត្រូវ អាចស្របទៅនឹងស្តង់ដាអន្តរជាតិ
- ការចំណាយសមហេតុសមផល វាធ្វើឱ្យមានការគ្រប់គ្រងការចំណាយលើទ្រព្យសកម្ម និងកំណត់តម្លៃខាតបង់បានត្រឹមត្រូវ។

CIAS-16 ក៏មានសារៈសំខាន់នៅក្នុងការពង្រឹងនូវគោលនយោបាយ និងបទប្បញ្ញត្តិដែលទាក់ទងនឹងការរាយការណ៍ហិរញ្ញវត្ថុដូចជា៖

- ការគ្រប់គ្រងទិន្នន័យហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព
- ការទប់ស្កាត់ការលួចបន្លំឬអំពើពុករលួយ
- ការបង្កើនសេចក្តីជឿជាក់លើអង្គភាពរដ្ឋ និងឯកជន អាចបង្ហាញពីការគ្រប់គ្រងហិរញ្ញវត្ថុដែលមានភាពច្បាស់លាស់ និងត្រឹមត្រូវ។

### ៣.២.២ គោលការណ៍ និងចំណុចសំខាន់

#### ក.ការទទួលស្គាល់

ការទទួលស្គាល់នូវទ្រព្យសកម្ម (Property, Plant, and Equipment - PPE) ត្រូវបានកំណត់យ៉ាងច្បាស់ក្នុងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ ។ ជាទូទៅ PPE ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មនៅពេលដែលមានលក្ខខណ្ឌខាងក្រោម៖

- មានអត្ថប្រយោជន៍សេដ្ឋកិច្ចពេលអនាគត ដោយ CIAS-16 បានប្រកាន់ខ្ជាប់ថា PPE ត្រូវបានទទួលស្គាល់ ប្រសិនបើវាបានបង្ហាញថាមានអត្ថប្រយោជន៍សេដ្ឋកិច្ចនៅក្នុងពេលអនាគត។ អត្ថប្រយោជន៍នេះរួម

មានដូចជា៖

- ការបង្កើតចំណូល ដោយអាចជួយឱ្យក្រុមហ៊ុនបង្កើតផលិតផល ឬក៏សេវាកម្មដែលទទួលបានចំណូល។
- ការប្រកបអាជីវកម្មបានកាន់តែប្រសើរ វាអាចធ្វើការកែលម្អការងារ និងប្រើប្រាស់នូវធនធានទាំងមូលបានយ៉ាងមានប្រសិទ្ធភាព។



- តម្លៃអាចវាយតម្លៃបានយ៉ាងត្រឹមត្រូវ ដោយការទទួលស្គាល់ PPE មិនអាចធ្វើបានទេបើតម្លៃមិនអាចវាយតម្លៃបានត្រឹមត្រូវ។ CIAS-16 បានកំណត់ថាក្រុមហ៊ុនអាចវាយតម្លៃទៅលើតម្លៃ PPE បានដោយប្រើប្រាស់នូវវិធីសាស្ត្រដូចជា៖
  - តម្លៃដើម (Cost) តម្លៃប្រើប្រាស់សម្រាប់ការទិញ PPE និងចំណាយផ្សេងទៀតដែលមានទាក់ទង ដូចជាចំណាយដឹកជញ្ជូន និងការតំឡើង។
  - ការវាយតម្លៃឡើងវិញ (Revaluation) ប្រសិនបើ PPE ត្រូវបានវាយតម្លៃឡើងវិញដោយសារតែតម្លៃទីផ្សារមានការកើនឡើង។
- អាយុកាលនៃការប្រើប្រាស់ PPE (Useful Life) គឺត្រូវបានធ្វើការកំណត់ក្នុងលក្ខខណ្ឌប្រើប្រាស់ដែលបានរំពឹងទុកនៃទ្រព្យសកម្មចំពោះអង្គភាព និងត្រូវបញ្ជាក់ថា វាអាចប្រើប្រាស់បានរហូតដល់អាយុកាលដែលបានកំណត់។
- ពេលដែល PPE ត្រូវបានប្រើប្រាស់ (Use of PPE) គឺនៅពេលដែល PPE ត្រូវបានដាក់ឱ្យប្រើប្រាស់

ហើយវាបន្តជួយក្នុងការផលិត ឬផ្តល់សេវាកម្មសម្រាប់ពេលអនាគត ។

- ការរក្សាទុក និងការរាយការណ៍ គឺបន្ទាប់ពីការទទួលស្គាល់ PPE រួច នោះវាត្រូវបានរក្សាទុក និងរាយការណ៍ទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយត្រូវគោរពនូវវិធាននៃការធ្វើរំលស់ (Depreciation) និងការធ្វើ (Impairment) ដែលធ្វើឱ្យវាមានភាពត្រឹមត្រូវ និងអាចប្រើប្រាស់បានល្អបំផុត។

ឧទាហរណ៍1: ក្រុមហ៊ុន ABC ទិញម៉ាស៊ីនផលិតកម្មក្នុងតម្លៃ $100,000។ នោះតម្លៃ វាអាចកំណត់បានដោយម៉ាស៊ីនអាចបង្កើតអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត នាំឱ្យវាត្រូវបានទទួលស្គាល់ជា PPE។

ការទទួលស្គាល់ PPE ត្រូវបានកំណត់ជាគោលការណ៍ដែលផ្អែកលើការប៉ាន់ប្រមាណពីអត្ថប្រយោជន៍សេដ្ឋកិច្ច និងតម្លៃអាចវាយតម្លៃបានយ៉ាងត្រឹមត្រូវ។ CIAS-16 បានផ្តល់នូវវិធីសាស្ត្រ និងមានលក្ខខណ្ឌច្បាស់លាស់សម្រាប់ការទទួលស្គាល់ PPE ដើម្បីធានាថាក្រុមហ៊ុនអាចរាយការណ៍ពីទ្រព្យសកម្មទៅក្នុងរបាយហិរញ្ញវត្ថុ ដោយសារតែវាបានបង្ហាញពីតម្លៃ និងអត្ថប្រយោជន៍ច្រើនដល់សេដ្ឋកិច្ច។

### ខ.ការវាស់វែង

ការវាស់វែងទ្រព្យសកម្ម (Property, Plant, and Equipment - PPE) ត្រូវបានអនុវត្តន៍នៅក្នុង CIAS-16 ដោយកំណត់វិធីសាស្ត្រវាស់វែង (Measurement) ជាពីរប្រភេទគឺ៖

1. ការវាស់វែងដំបូង (Initial Measurement) ៖ នៅពេលក្រុមហ៊ុនទទួលស្គាល់ ទ្រព្យសកម្ម វាត្រូវបានវាស់វែងនៅតម្លៃដើម (Cost Model) ។ តម្លៃដើមរួមមានដូចជា៖

- តម្លៃទិញ (Purchase Price)
- អាករ និងពន្ធ (Taxes & Import Duties)
- ការដឹកជញ្ជូន (Transportation Costs)
- ការតំឡើង និងការធ្វើតេស្ត (Installation & Testing Costs)
- ការចំណាយបន្ថែមដើម្បីឱ្យទ្រព្យសកម្មនោះវាអាចប្រើប្រាស់បាន។

ឧទាហរណ៍៖ ក្រុមហ៊ុន ABC ទិញម៉ាស៊ីនក្នុងតម្លៃ $50,000 ក្នុងនោះមានចំណាយដឹកជញ្ជូន $2,000 រួមទាំងចំណាយដំឡើង និងសាកល្បង $3,000។ ដូចនេះ តម្លៃដើម (Initial Measurement) = $55,000 ។

2. ការវាស់វែងបន្ត (Subsequent Measurement)៖ បន្ទាប់ពីទទួលស្គាល់ទ្រព្យសកម្ម ក្រុមហ៊ុនអាចជ្រើសរើសវិធីសាស្ត្រវាស់វែងបន្ត ជាពីរប្រភេទគឺ៖

- វិធីសាស្ត្រតម្លៃដើម (Cost Model) ដោយ PPE ត្រូវបានវាស់វែងទៅតាមតម្លៃដើមដោយដកចេញនូវរំលស់ (Depreciation) និងការខាតបង់ពីការធ្លាក់ចុះតម្លៃ (Impairment) យ៉ាងត្រឹមត្រូវនៅក្នុងរយៈពេលប្រើប្រាស់ PPE ។

- តម្លៃដើម គឺជាតម្លៃដែលបានបង់សម្រាប់ទិញ PPE ព្រមទាំងការចំណាយផ្សេងៗ ដូចជាការដឹកជញ្ជូន និងការតំឡើង។
- Depreciation ត្រូវតែធ្វើទៅលើអាយុកាលនៃការប្រើប្រាស់ទ្រព្យសកម្ម (Useful Life) និងអត្រារំលស់ (Depreciation Rate) ។ ដោយគេអាចប្រើប្រាស់វាទៅតាមវិធីសាស្ត្រជាច្រើនដូចជា វិធីសាស្ត្ររំលស់ថេរ វិធីសាស្ត្ររំលស់ទ្វេរភាគ វិធីសាស្ត្ររំលស់ថយចុះជាលំដាប់ និងវិធីសាស្ត្ររំលស់តាមផលបូកតួលេខនៃឆ្នាំរំលស់។

- ការធ្វើ Impairment គឺជាការធ្វើលើការខាតបង់នូវតម្លៃ PPE ប្រសិនបើវាមិនអាចបង្កើតចំណូលសេដ្ឋកិច្ចដែលបានប៉ាន់ប្រមាណឡើងវិញ។

ឧទាហរណ៍៖ ម៉ាស៊ីនដែលទិញក្នុងតម្លៃ $55,000 មានអាយុកាលប្រើប្រាស់ 10 ឆ្នាំ។ នោះតម្លៃ Depreciation ប្រចាំឆ្នាំ = $5,500 (ប្រើវិធី Straight-Line )។



- វិធីសាស្ត្រវាយតម្លៃឡើងវិញ (Revaluation Model) ដោយ PPE ត្រូវបានវាយតម្លៃសារជាថ្មីនៅពេលណាមួយដែលមានការកំណត់តម្លៃទីផ្សារ និងត្រូវបានសន្និដ្ឋានថាជាតម្លៃដែលអាចទទួលយកបាន។ ប្រសិនបើការវាយតម្លៃឡើងវិញមានការធ្លាក់ចុះតម្លៃ នោះវានឹងបង្ហាញពីការបាត់បង់ជាលក្ខណៈ Impairment ។

ឧទាហរណ៍៖ ម៉ាស៊ីនមួយគ្រឿងទិញក្នុងតម្លៃ = $40,000 រំលស់រយៈពេល 10ឆ្នាំ ដោយធ្វើតាមវិធីសាស្ត្ររំលស់ថេរ (Straight-Line) និងមានតម្លៃទីផ្សារ = $35,000 ។

-រកតម្លៃ Book Value Or Carrying Amount

ដោយ Depreciation = $\frac{40,000}{10} = 4,000^{\$}$

→ Carrying Amount = 40,000 – 4,000 = 36,000$^{\$}$

គេបាន Carrying Amount = 36,000 > Fv = 35,000 → Impairment Loss = $1,000 ។

### គ.ការលែងទទួលស្គាល់

ការលែងទទួលស្គាល់ (Derecognition) នៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ គឺត្រូវបានអនុវត្តនៅពេលដែលទ្រព្យសកម្ម (Property, Plant, and Equipment- PPE) ត្រូវបានលក់ចេញ មិនត្រូវបានប្រើប្រាស់តទៅទៀត និងលែងមានអត្ថប្រយោជន៍សម្រាប់សេដ្ឋកិច្ច។ចំណុចសំខាន់ៗនៃការលែងទទួលស្គាល់

(Derecognition) ក្នុង CIAS-16 មាន៖

- ការលក់ PPE ដោយនៅពេលដែល PPE ត្រូវបានលក់ចេញ នោះវាត្រូវបានលែងទទួលស្គាល់នៅក្នុងបញ្ជីហិរញ្ញវត្ថុ ហើយតម្លៃលក់ និងប្រាក់ចំណេញ ឬការខាតបង់ពីការលក់ត្រូវតែចុះទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- បាត់បង់ជាពហុភាព នៅពេលដែល PPE ត្រូវបានបាត់បង់ដោយសារបំផ្លាញ ឬពុំមានប្រយោជន៍ដើម្បីប្រើប្រាស់តទៅទៀត ក្រុមហ៊ុនត្រូវបញ្ចូលវាជាផ្នែកនៃការលែងទទួលស្គាល់។
- ការបញ្ចប់អាយុកាលប្រើប្រាស់ នៅពេលដែល PPE មិនអាចផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតទៀត ដូចជាប្រើហួតដល់ពុំអាចជួសជុលបាន ក៏ត្រូវបានលែងទទួលស្គាល់ផងដែរ។

### ឃ.ការលាតត្រដាង

ការលាតត្រដាង (Disclosure) មានសារៈសំខាន់ក្នុងការបង្ហាញពីព័ត៌មានសំខាន់ៗ ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងច្បាស់លាស់ក្នុងការរាយការណ៍ហិរញ្ញវត្ថុ។ ការលាតត្រដាងត្រូវតែធ្វើឡើងដើម្បីឱ្យមានការយល់ដឹងច្បាស់អំពីគោលការណ៍ និងវិធីសាស្ត្រដែលក្រុមហ៊ុនប្រើប្រាស់ក្នុងការអនុវត្តន៍ CIAS-16 ។ ខាងក្រោមនេះជាចំណុចសំខាន់ៗនៃការលាតត្រដាង រួមមាន៖

- ការលាតត្រដាងពីប្រភេទនៃPPE (Property, Plant, and Equipment) ក្រុមហ៊ុនត្រូវតែបង្ហាញប្រភេទនៃ PPE ដែលមានដូចជា អគារ របនាសម្ព័ន្ធ ម៉ាស៊ីនឧស្សាហកម្ម ផ្សេងៗជាដើម។
- ការលាតត្រដាងពីការវាស់វែងPPE ក្រុមហ៊ុនត្រូវតែបង្ហាញពីវិធីសាស្ត្រនៃការវាស់វែង PPE ដូចជា វិធីសាស្ត្រតម្លៃដើម (Cost Model) ឬ វិធីសាស្ត្រវាយតម្លៃឡើងវិញ (Revaluation Model) ដែលទាក់ទងនឹងការកើនឡើង ឬធ្លាក់ចុះនៃតម្លៃបន្ទាប់ពីបានធ្វើការវាយតម្លៃឡើងវិញ។



- ការលាតត្រដាងពីការផ្លាស់ប្តូរនៃ PPE ក្រុមហ៊ុនត្រូវតែបង្ហាញពីការផ្លាស់ប្តូរប្រភេទនៃ PPE ដែលបានកំណត់សំខាន់ៗ សម្រាប់ការប្រើប្រាស់នៅក្នុងអាជីវកម្ម។
- ការលាតត្រដាងពីការលែងទទួលស្គាល់ PPE ក្រុមហ៊ុនត្រូវតែបង្ហាញពីការលែងទទួលស្គាល់ PPE ឬការលក់ PPE ទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុបន្ទាប់ពីលក់ PPE ឬបាត់បង់ ដោយព័ត៌មាននេះបង្ហាញពីប្រាក់ចំណេញ ឬការខាតបង់ ។
- ការលាតត្រដាងពីការបញ្ចូលទ្រព្យសកម្ម ព័ត៌មានអំពីការបញ្ចូល PPE ដែលបានប្រើប្រាស់នៅក្នុងផលិតកម្ម ឬដំណើរការបច្ចេកវិទ្យាផ្សេងៗ ត្រូវតែបង្ហាញនូវហេតុផល កាលបរិច្ឆេទ និងតម្លៃឱ្យបានត្រឹមត្រូវ។
- អាយុកាលនៃការប្រើប្រាស់ PPE (Useful Life) ក្រុមហ៊ុនត្រូវតែបង្ហាញអំពីអាយុកាលនៃការប្រើប្រាស់ទ្រព្យសកម្ម ថាជាអាយុកាលជាក់លាក់ ឬអាយុកាលមិនច្បាស់លាស់ ដើម្បីជួយឱ្យអ្នកប្រើប្រាស់របាយការណ៍មានភាពយល់ដឹងបានកាន់តែច្បាស់។
- វិធីសាស្ត្ររំលស់ (Depreciation Method) ត្រូវបង្ហាញពីវិធីសាស្ត្រដែលបានប្រើដើម្បីប៉ាន់ប្រមាណលើការធ្វើរំលស់ដូចជាStraight-line Method, Declining balance Method ឬSum of the Year Degit method ។
- អត្រារំលស់ប្រចាំឆ្នាំ (Depreciation Rates) បង្ហាញអត្រារំលស់ប្រចាំឆ្នាំសម្រាប់ប្រភេទនីមួយៗនៃ PPE ដើម្បីបង្ហាញថាការប្រែក្លាយនៃតម្លៃត្រូវបានគណនាដូចម្តេច។
- ការធ្វើការត្រួតពិនិត្យឡើងវិញ ត្រូវតែបង្ហាញពីការធ្វើការត្រួតពិនិត្យឡើងវិញនៃអាយុកាលប្រើប្រាស់ឬតម្លៃសំណល់ (Residual Value) នៅគ្រប់ពេលចប់ឆ្នាំហិរញ្ញវត្ថុ។
- បង្ហាញអំពីបញ្ហាបាត់បង់តម្លៃ (Impairment) បើ PPE មានបញ្ហាបាត់បង់តម្លៃ ត្រូវបង្ហាញព័ត៌មានពីចំណុចដែលប៉ះពាល់ដល់តម្លៃសំណល់នៃទ្រព្យសកម្មនោះ។

### ៣.២.៣ សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦

#### ក.ការធានាភាពត្រឹមត្រូវ និងសុចរិតនៃរបាយការណ៍ហិរញ្ញវត្ថុ

ការធានាថារបាយការណ៍ហិរញ្ញវត្ថុមានភាពត្រឹមត្រូវ និងសុចរិត គឺជាបំណងដ៏សំខាន់របស់និយ័តករគណនេយ្យ និងសវនកម្ម ដើម្បីធានាថាព័ត៌មានហិរញ្ញវត្ថុដែលបានបង្ហាញអាចជឿទុកចិត្តបាន សម្រាប់ការសម្រេចចិត្តរបស់ភាគីពាក់ព័ន្ធ។ ការធានានេះត្រូវបានអនុវត្តតាមវិធីដូចខាងក្រោម៖

**១. ការអនុវត្តស្តង់ដាគណនេយ្យ និងសវនកម្ម**

- ប្រើប្រាស់ ស្តង់ដាសវនកម្មអន្តរជាតិ (ISA) ក្នុងការត្រួតពិនិត្យ និងវាយតម្លៃរបាយការណ៍ហិរញ្ញវត្ថុ
- អនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ ក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឱ្យត្រឹមត្រូវ។

**២. ការប្រតិបត្តិការសវនកម្ម**

- ពិនិត្យលើភាពត្រឹមត្រូវនៃទិន្នន័យហិរញ្ញវត្ថុ និងឯកសារកំណត់ត្រាទាំងអស់
- វាយតម្លៃការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង (Internal Control) របស់សហគ្រាស
- ពិនិត្យសំណុំឯកសារតំណាងឱ្យប្រតិបត្តិការផ្សេងៗ ដើម្បីធានាភាពត្រឹមត្រូវ
- បង្ហាញការផ្តល់យោបល់សវនកម្ម អំពីរបាយការណ៍ហិរញ្ញវត្ថុ។

## ៣. ការផ្តល់យោបល់សវនកម្ម

- បន្ទាប់ពីសវនកម្ម និយ័តករនឹងផ្តល់យោបល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ដោយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវតែមានភាពត្រឹមត្រូវ ច្បាស់លាស់ និងសុចរិតគ្រប់គ្រាន់ ត្រូវចំណាំថាមិនត្រូវផ្តល់ព័ត៌មានក្លែងបន្លំ ហើយព័ត៌មានត្រូវមានគ្រប់គ្រាន់សម្រាប់ធ្វើការវាយតម្លៃ។

## ៤. ការធានាភាពត្រឹមត្រូវ និងសុចរិតនៃរបាយការណ៍ហិរញ្ញវត្ថុ

- បង្កើនភាពទុកចិត្តពីសាធារណៈ និងភាគីពាក់ព័ន្ធលើរបាយការណ៍ហិរញ្ញវត្ថុ
- ជួយឱ្យអាជីវកម្មអាចទទួលបានការវិនិយោគ ឬប្រាក់កម្ចីពីធនាគារ
- ការពារភាពសុចរិត និងកាត់បន្ថយហានិភ័យក្លែងបន្លំ។




## ៥. ការបង្កើនប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង

- CIAS-16 ជួយកំណត់និងពិនិត្យសភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការធានាភាពត្រឹមត្រូវនៃទិន្នន័យហិរញ្ញវត្ថុ
- ជួយសម្គាល់ចំណុចខ្សោយក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងផ្តល់អនុសាសន៍ ដើម្បីធ្វើឱ្យប្រព័ន្ធមានភាពរឹងមាំ។

**៦. ការលើកកម្ពស់សុវត្ថិភាពនៃទិន្នន័យ និងការចូលដំណើរការបានត្រឹមត្រូវ**

- បង្កើនការការពារទិន្នន័យហិរញ្ញវត្ថុពីការចូលប្រើដោយអ្នកគ្មានកាតព្វកិច្ច
- ការគ្រប់គ្រងលើឯកសារដែលពាក់ព័ន្ធជួយធានាថាការបង្ហាញទិន្នន័យមានភាពត្រឹមត្រូវ។

**៧. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របនឹងគោលការណ៍សុចរិត និងភាពស្មោះត្រង់**

- ជួយឱ្យនិយ័តករមានវិធីសាស្ត្រដែលច្បាស់លាស់ក្នុងការវាយតម្លៃលើភាពស្មោះត្រង់នៃការរៀបចំរបាយការណ៍
- ជួយប្រមូល និងគាំទ្រព័ត៌មានដោយផ្អែកលើសំណុំឯកសារដែលអាចត្រួតពិនិត្យបាន។

**៨. ការរួមចំណែកសំខាន់ក្នុងការបង្កើតការអភិវឌ្ឍន៍ត្រឹមត្រូវទៅលើផ្នែកហិរញ្ញវត្ថុ**

- ជួយស្ថាបនាអភិវឌ្ឍន៍ក្នុងការរួមចំណែកចំពោះភាពសុចរិតនៃរបាយការណ៍
- បណ្តុះបណ្តាលដល់បុគ្គលិកឱ្យយល់នូវសារៈសំខាន់នៃសីលធម៌វិជ្ជាជីវៈ និងការធ្វើរបាយការណ៍យ៉ាងម៉ត់ចត់។

### ខ.ការជំរុញការវិនិយោគ

ការអនុវត្ត CIAS-16 មានសារៈសំខាន់ជាច្រើនក្នុងការជំរុញការវិនិយោគនៅលើទីផ្សារ និងនៅក្នុងអាជីវកម្ម រួមមាន៖

- បង្កើនការទំនាក់ទំនង និងការផ្តល់ទំនុកចិត្ត ការអនុវត្តតាម CIAS-16 ប្រកបដោយភាពត្រឹមត្រូវ និងភាពទាន់សម័យក្នុងការរាយការណ៍ហិរញ្ញវត្ថុ ជួយបង្កើននូវទំនុកចិត្តដល់អ្នកវិនិយោគទាំងក្នុងប្រទេស និងក្រៅប្រទេស ដោយបានធ្វើឱ្យពួកគេឃើញថាអាជីវកម្មនៅក្នុងស្ថាប័នមានការរាយការណ៍ហិរញ្ញវត្ថុ



ស្របតាមគោលការណ៍ស្តង់ដាអន្តរជាតិ ។

- ភាពច្បាស់លាស់នៅក្នុងការរាយការណ៍ហិរញ្ញវត្ថុ ដោយបានបង្កើននូវការសម្រេចចិត្តដ៏ល្អសម្រាប់អ្នកវិនិយោគ ផ្តល់ព័ត៌មានហិរញ្ញវត្ថុដែលត្រឹមត្រូវ និងមានប្រសិទ្ធភាព។ ហើយអ្នកវិនិយោគ អាចធ្វើការវិនិយោគបានយ៉ាងល្អប្រសើរ ដោយសារបានស្វែងយល់ពីស្ថានភាពហិរញ្ញវត្ថុ និងវិស័យទីផ្សារផ្សេងៗនៅក្នុងប្រទេសកម្ពុជា។
- ការពង្រឹងភាពប្រកួតប្រជែង សហគ្រាសអាចធ្វើបច្ចុប្បន្នភាពគណនេយ្យតាមស្តង់ដាអន្តរជាតិ ដើម្បីអាចប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិក្នុងការទាក់ទាញការវិនិយោគចូលក្នុងប្រទេស។
- ការកាត់បន្ថយការបាត់បង់ហិរញ្ញវត្ថុ ការអនុវត្ត CIAS-16 ជួយជៀសវាងការវិនិយោគដែលមានការប្រកួតប្រជែងអស្ថិរភាព វាអាចជួយធ្វើឱ្យប្រទេសកម្ពុជាកាន់តែមានភាពទាក់ទាញពីការវិនិយោគដែលមាននូវស្ថិរភាពក្នុងការសម្រេចចិត្តរយៈពេលវែង។
- ការរួមបញ្ចូលជាមួយប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ CIAS-16 ជួយធ្វើឱ្យអាជីវកម្មនៅកម្ពុជាអាចបង្ហាញនូវអត្តសញ្ញាណនៃការរាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាអន្តរជាតិ ដែលអាចធ្វើឱ្យស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារពិភពលោកទទួលស្គាល់ និងងាយស្រួលក្នុងការផ្តល់ឥណទាន ឬវិនិយោគ។
- ការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុក្នុងសហគ្រាស ការអនុវត្ត CIAS-16 អនុញ្ញាតឱ្យអាជីវកម្មមានប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងទ្រព្យសកម្មមានស្ថិរភាព ច្បាស់លាស់ ដែលជួយឱ្យការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុមានគុណភាពខ្ពស់។
- ការផ្តល់ភាពស្មើគ្នាដល់អាជីវកម្មក្នុងប្រទេស និងក្រៅប្រទេស អាជីវកម្មក្នុងប្រទេសអាចប្រកួតប្រជែងយ៉ាងស្មើភាពនឹងក្រុមហ៊ុនអន្តរជាតិដោយសារតែមានស្តង់ដារាយការណ៍ដូចគ្នា បង្កើនឱកាសរកដៃគូ និងទាក់ទាញអ្នកវិនិយោគ។
- ការបង្កើនភាពជឿជាក់នៅលើអ្នកគ្រប់គ្រង ព័ត៌មានហិរញ្ញវត្ថុដែលអនុវត្តតាម CIAS-16 អាចជួយឱ្យម្ចាស់អាជីវកម្ម និងអ្នកវិនិយោគ មានភាពជឿជាក់លើសមត្ថភាពគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។
- ការលើកកម្ពស់ធន្ទៈនៃការចូលទីផ្សារផ្សេងទៀត ជាពិសេសសម្រាប់ក្រុមហ៊ុនដែលចង់ចុះបញ្ជីនៅក្នុងផ្សារហ៊ុន ឬបើកការវិនិយោគគ្រប់គ្រងជាមួយបរទេស មានការបង្ហាញថាគាត់អាចអនុវត្តតាមស្តង់ដាអន្តរជាតិបានយ៉ាងល្អប្រសើរ។

សរុបមក CIAS-16 បានផ្តល់នូវប្រសិទ្ធភាពក្នុងការត្រួតពិនិត្យ និងការរាយការណ៍ហិរញ្ញវត្ថុដោយមានការលើកទឹកចិត្តឱ្យមានការវិនិយោគបន្ថែម ដើម្បីអាចប្រកួតប្រជែងលើកម្រិតអន្តរជាតិបាន។

### គ.ការគ្រប់គ្រងប្រសិទ្ធភាពទ្រព្យសកម្ម

CIAS-16 (Cambodian International Accounting Standard -16) គឺជាស្តង់ដាគណនេយ្យអន្តរជាតិស្តីពីទ្រព្យសកម្ម (Property, Plant, and Equipment - PPE) ដែលស្ថាប័ន ឬសហគ្រាសអាចអនុវត្តន៍ ដើម្បីគ្រប់គ្រងប្រសិទ្ធភាពនៃទ្រព្យសកម្មរបស់ខ្លួន។ ការគ្រប់គ្រងប្រសិទ្ធភាពនៃទ្រព្យសកម្ម គឺជាការប្រើប្រាស់នូវធនធានទ្រព្យសកម្មដែលមានឱ្យបានប្រសើរ និងមានប្រសិទ្ធភាពក្នុងការប្រកបអាជីវកម្ម។ ទ្រព្យសកម្ម គឺជា

ទ្រព្យទាំងឡាយណាដែលទិញមកគ្មានគោលបំណងក្នុងការលក់ចេញ ទុកប្រើប្រាស់នៅក្នុងអាជីវកម្ម មានអាយុកាលប្រើប្រាស់លើសពីមួយឆ្នាំ និងជាកម្មវត្ថុសម្រាប់ការធ្វើរំលស់ (មានដូចជា ផ្ទះឧបករណ៍ ម៉ាស៊ីន និងយានយន្តដឹកជញ្ជូនជាដើម)។ ការអនុវត្តស្តង់ដានេះ បានផ្តល់មកនូវសារៈសំខាន់ជាច្រើនដល់ការគ្រប់គ្រងប្រសិទ្ធភាពនៃទ្រព្យសកម្ម ដែលរួមមានដូចជា៖

- ការគណនាតម្លៃទ្រព្យសកម្មបានត្រឹមត្រូវ CIAS-16 កំណត់វិធានការច្បាស់លាស់សម្រាប់ការបង្ហាញតម្លៃទ្រព្យសកម្មដោយប្រើវិធីសាស្ត្រ Cost Model ឬ Revaluation Model។ វាជួយឱ្យសហគ្រាសបញ្ជាក់នូវតម្លៃកែតម្រូវរបស់ទ្រព្យសកម្ម និងស្វែងរកវិធីសាស្ត្រក្នុងការបន្តការប្រើប្រាស់ទ្រព្យសកម្មឱ្យមានប្រសិទ្ធភាពខ្ពស់។



- ការធ្វើរំលស់ (Depreciation) ត្រឹមត្រូវ សហគ្រាសអាចកំណត់អត្រានៃការធ្វើរំលស់បានត្រឹមត្រូវដោយយោងទៅតាមអាយុកាលនៃការប្រើប្រាស់ទ្រព្យសកម្ម។ វាមានសារៈសំខាន់ក្នុងការកំណត់បែបបទនៃ Depreciation Methods (វិធីសាស្ត្ររំលស់ថេរ វិធីសាស្ត្ររំលស់ទ្វេរភាគ វិធីសាស្ត្ររំលស់ថយចុះជាលំដាប់ និងវិធីសាស្ត្ររំលស់តាមផលបូកតួលេខនៃឆ្នាំរំលស់) ដើម្បីឱ្យការគណនារំលស់នៃទ្រព្យសកម្មនៅក្នុងសហគ្រាសស្របតាមស្ថានភាពពិត និងជួយបែងចែកទៅលើការខាតបង់នូវតម្លៃនៃទ្រព្យសកម្ម (Impairment of Assets) ឱ្យបានត្រឹមត្រូវសមស្របជាមួយអាយុកាលប្រើប្រាស់។
- ការពង្រឹងសមត្ថភាពអាជីវកម្ម ដោយការគ្រប់គ្រងប្រសិទ្ធភាពនៃទ្រព្យសកម្ម ជួយធ្វើឱ្យក្រុមហ៊ុនអាចពង្រីកសមត្ថភាពប្រកបអាជីវកម្មបានកាន់តែល្អ ។
- ការទទួលបានប្រាក់ចំណេញ ការគ្រប់គ្រងប្រសិទ្ធភាពនៃទ្រព្យសកម្មអាចជួយបញ្ជាក់ពីការប្រើប្រាស់

ទ្រព្យសកម្មឱ្យមានអត្ថប្រយោជន៍ និងផ្ដល់ការចំណេញទៅកាន់ក្រុមហ៊ុន។

- ការសន្សំប្រាក់ និងការបង្កើនប្រសិទ្ធភាព ការគ្រប់គ្រងទ្រព្យសកម្មឱ្យមានប្រសិទ្ធភាពអាចកាត់បន្ថយការចំណាយនៅលើការជួសជុល និងការថែទាំដែលចាំបាច់ ហើយការអភិវឌ្ឍន៍នូវប្រព័ន្ធថែទាំអាចនាំឱ្យមានការចំណាយទាប។
- ប្រាកដភាព និងត្រឹមត្រូវក្នុងការរាយការណ៍ហិរញ្ញវត្ថុ ការចងក្រង និងការរាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានភាពត្រឹមត្រូវ និងអាចជឿទុកចិត្តបាន។ រំលឹកឱ្យសហគ្រាសបែងចែកឱ្យបានត្រឹមត្រូវអំពីការចំណាយលើទ្រព្យសកម្ម និងការចំណាយលើប្រតិបត្តិ ហើយជួយឱ្យអ្នកមានភារកិច្ចគ្រប់គ្រងហិរញ្ញវត្ថុអាចអធិប្បាយពន្យល់អំពីស្ថានភាពហិរញ្ញវត្ថុបានត្រឹមត្រូវ។
- ការអភិវឌ្ឍន៍ និងការបំពេញតាមច្បាប់នៃស្តង់ដា វាជួយធ្វើឱ្យសហគ្រាសអាចបំពេញតាមបទដ្ឋានគណនេយ្យ និងតាមច្បាប់ដែលពាក់ព័ន្ធ។
- ការសម្រួលដល់ការទាក់ទងជាមួយអ្នកដែលមានការចាប់អារម្មណ៍ (Investors & Stakeholders) ការរក្សាប្រតិបត្តិការច្បាស់លាស់អំពីតម្លៃទ្រព្យសកម្មនឹងបង្កើនការជឿជាក់ពីភាគីដែលពាក់ព័ន្ធ។ ចំណែកឯអ្នកវិនិយោគ និងភាគីសេដ្ឋកិច្ចផ្សេងៗ អាចប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុសម្រាប់ការសម្រេចចិត្តអំពីការវិនិយោគ និងការប្រើប្រាស់ធនធាន។

ការអនុវត្ត (CIAS-16) បានយ៉ាងត្រឹមត្រូវជួយឱ្យសហគ្រាសមានគោលការណ៍គ្រប់គ្រងទ្រព្យសកម្មប្រកបដោយប្រសិទ្ធភាពដែលជួយឱ្យមានការរៀបចំលើការរាយការណ៍ហិរញ្ញវត្ថុបានច្បាស់លាស់ ប្រកបដោយភាពត្រឹមត្រូវ និងអាចជឿទុកចិត្ត។ វាជាកត្តាជំរុញឱ្យសហគ្រាសអាចប្រកួតប្រជែងបានល្អក្នុងទីផ្សារ និងបំពេញតាមបទដ្ឋានគណនេយ្យអន្តរជាតិបានយ៉ាងត្រឹមត្រូវ។

### ៣.៣ ផលប៉ះពាល់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ចំពោះប្រតិបត្តិការអាជីវកម្ម

ការអនុវត្ត CIAS-16 មានផលប៉ះពាល់មួយចំនួនទៅលើរបាយការណ៍ហិរញ្ញវត្ថុចំពោះប្រតិបត្តិការអាជីវកម្មដូចជា៖

- តម្លៃទ្រព្យសកម្មអាចត្រូវប៉ាន់ប្រមាណផ្អែកលើវិធីសាស្រ្តតម្លៃដើម (Cost Model) ឬវិធីសាស្រ្តវាយតម្លៃឡើងវិញ (Revaluation Model)។ ប្រសិនបើជ្រើសរើស Revaluation Model នឹងមានការកែប្រែជាញឹកញាប់ទៅលើតម្លៃទ្រព្យសកម្មដែលធ្វើឱ្យប៉ះពាល់ដល់របាយការណ៍ចំណេញ/ខាត (Profit / Loss)។
- ផលប៉ះពាល់លើប្រាក់ចំណេញ ការធ្វើរំលស់ត្រូវគណនាដោយផ្អែកលើអាយុកាលប្រើប្រាស់ និងវិធីសាស្រ្តរំលស់ដែលបានជ្រើសរើស។ ប្រសិនបើអាយុកាលប្រើប្រាស់មិនបានប៉ាន់ស្មានត្រឹមត្រូវ នោះអាចធ្វើឱ្យប្រាក់ចំណេញមិនមានស្ថិរភាព។ ហើយការធ្វើរំលស់ទៅលើទ្រព្យសកម្ម អាចធ្វើឱ្យប្រាក់ចំណេញបណ្តោះអាសន្ន (Short-term Profits) ប្រែប្រួល ហើយវាអាចបណ្តាលឱ្យប៉ះពាល់ដល់សមិទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។
- ការចំណាយថវិកាក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទ្រព្យសកម្ម គឺក្រុមហ៊ុនត្រូវការប្រើប្រាស់នូវប្រព័ន្ធទិន្នន័យសម្រាប់ការកត់ត្រា និងគ្រប់គ្រងទ្រព្យសកម្មដូចជា កែសម្រួលប្រព័ន្ធគណនេយ្យដើម្បីឱ្យការគណនាបានត្រឹមត្រូវ ធ្វើការបណ្តុះបណ្តាលដល់បុគ្គលិក ដើម្បីមានសមត្ថភាពប្រើប្រាស់ប្រព័ន្ធកាន់តែមានប្រសិទ្ធភាព ចំណាយលើថ្លៃការជួល ឬទិញប្រព័ន្ធ Software សម្រាប់កត់ត្រាទិន្នន័យទាំងអស់។
- ផលប៉ះពាល់លើការផ្តល់ប្រាក់កម្ចី និងការវិនិយោគ ធនាគារ និងអ្នកវិនិយោគស្វាបស្ទង់តម្លៃនៃទ្រព្យ

សកម្មដើម្បីកំណត់ថាតើក្រុមហ៊ុនមានសមត្ថភាពសងបំណុលឬទេ។ ហើយប្រសិនបើការរៀបចំរបាយការណ៍មិនបានត្រឹមត្រូវ ឬការរាយការណ៍មិនមាននូវតម្លាភាព អាចបណ្ដាលឱ្យមាននូវការបញ្ឈប់ការផ្ដល់ប្រាក់កម្ចី។

- ផលប៉ះពាល់លើការដំឡើងតម្លៃ និងការបង់ពន្ធ ប្រសិនបើមានការដំឡើងតម្លៃលើទ្រព្យសកម្ម នោះវាអាចប៉ះពាល់ដល់ការគណនាពន្ធលើប្រាក់ចំណេញ ហើយការផ្លាស់ប្ដូរតម្លៃអាចបណ្ដាលឱ្យមានការប្រែប្រួលក្នុងអត្រាពន្ធ (Tax Rate)។
- ផលប៉ះពាល់លើបុគ្គលិកនិងសមត្ថភាពជំនាញបច្ចេកទេស ក្នុងការអនុវត្ត CIAS-16 ឱ្យបានទៀងទាត់តម្រូវឱ្យបុគ្គលិកគណនេយ្យត្រូវតែមានចំណេះដឹងច្បាស់លាស់លើការគណនា Depreciation, Impairment, Revaluation...។ ប្រសិនបើសមត្ថភាពមិនគ្រប់គ្រាន់ អាចនាំឱ្យមានកំហុសកើតមានឡើងផងដែរ។
- ផលប៉ះពាល់លើសីលធម៌វិជ្ជាជីវៈ និងភាពជឿជាក់ ការអនុវត្ត CIAS-16 មិនបានត្រឹមត្រូវ នោះវាអាចបណ្ដាលឱ្យមាននូវការបង្ហាញព័ត៌មានក្លែងក្លាយដែលអាចប៉ះពាល់ដល់ភាពជឿជាក់របស់អង្គភាពជាមួយភាគីខាងក្រៅ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវអស់រយៈពេលកន្លងមកនេះ ក្រុមរបស់នាងខ្ញុំ បានប្រមូលព័ត៌មាន និងទិន្នន័យសំខាន់ៗជាច្រើន ទុកជាដើមទុនដើម្បីធ្វើការវិភាគ វាស់វែង និងវាយតម្លៃពីសារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ (CIAS-16) ហើយក្នុងនោះផងដែរ ក្រុមនាងខ្ញុំបានសង្កេតមើលឃើញថាមាននូវចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនដែលមានដូចខាងក្រោមៈ

## ៤.១ ការវិភាគលើចំណុចខ្លាំង

- សហគ្រាសមានការអនុវត្តស្របទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ បានត្រឹមត្រូវ ដោយការអនុវត្ត CIAS-16 ជាចំណុចសំខាន់សម្រាប់ធានាថាការរៀបចំ និងការរាយការណ៍ទិន្នន័យទាំងអស់ទាក់ទងនឹងទ្រព្យសកម្ម (PPE) ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ និងមានសុពលភាព។ វាជួយផ្តល់ភាពជឿជាក់ និងគុណភាពខ្ពស់ដល់របាយការណ៍ហិរញ្ញវត្ថុ ដែលជាជម្រើសសំខាន់សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានរបស់អ្នកវិនិយោគ អ្នកផ្តល់កម្ចី និងអាជ្ញាធរពាក់ព័ន្ធ។
- ការគ្រប់គ្រងទ្រព្យសកម្ម (PPE) បានកាន់តែល្អប្រសើរ ដោយសហគ្រាសអាចតាមដាន អភិរក្ស និងប្រើប្រាស់ទ្រព្យសកម្មបានល្អជាងមុន។ វាជួយបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធាន និងកាត់បន្ថយការចំណាយដោយខាតឥណទាន ឬការបាត់បង់ទ្រព្យសកម្មដែលមិនបានគ្រប់គ្រងល្អ។
- ការរៀបចំទិន្នន័យនៃរបាយការណ៍ហិរញ្ញវត្ថុបានត្រឹមត្រូវ ច្បាស់លាស់ ហើយវាជួយឱ្យការប្រើប្រាស់ទិន្នន័យសម្រាប់វិភាគ ធ្វើការព្យាករណ៍ និងសម្រេចចិត្តលើការវិនិយោគ ឬការគ្រប់គ្រងខាងក្នុងកាន់តែមានប្រសិទ្ធភាព។
- លើកកម្ពស់ដល់ការវិនិយោគ ដោយធានាឱ្យមាននូវភាពជឿជាក់ពីគ្រប់ភាគីវិនិយោគ និងអ្នកផ្តល់កម្ចី ហើយវាក៏បានបង្កើនការវិនិយោគបានកាន់តែច្រើនទាំងក្នុង និងក្រៅប្រទេស។ របាយការណ៍ហិរញ្ញវត្ថុដែលអនុវត្តស្របតាមស្តង់ដាត្រឹមត្រូវ នឹងធ្វើឱ្យភាគីខាងក្រៅមានភាពជឿជាក់លើសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុ។ វាជួយបង្កើនការទាក់ទាញវិនិយោគ និងធនធានហិរញ្ញវត្ថុថ្មី ដោយសម្គាល់ថាសហគ្រាសមានគ្រប់លក្ខណៈក្នុងការអភិវឌ្ឍន៍ និងធានាបាននូវផលចំណេញ។
- ការប្រើប្រាស់វិធីសាស្ត្រដែលមានប្រសិទ្ធភាព ដើម្បីធ្វើការគណនាតម្លៃនៃទ្រព្យសកម្ម ការធ្វើរំលស់ទៅតាមអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម និងការធ្វើ Impairment បានត្រឹមត្រូវ។ ការប្រើប្រាស់នូវវិធីសាស្ត្រដូចជា straight-line depreciation ឬ declining balance method បន្សល់ភាពស្មើភាព និងភាពជាក់លាក់ក្នុងការកំណត់តម្លៃ។ ជាពិសេស ការធ្វើ impairment test សមស្របធានាឱ្យមានការបង្ហាញតម្លៃទ្រព្យសកម្មត្រឹមត្រូវបំផុត ដែលជួយកាត់បន្ថយហានិភ័យនៃការផ្តល់ព័ត៌មានខុសឆ្គង។
- ការប្រើប្រាស់នូវប្រព័ន្ធគណនេយ្យស្របតាមស្តង់ដាគណនេយ្យអន្តរជាតិ ដែលមានភាពងាយស្រួលដល់ការអនុវត្តការងារនៅក្នុងស្ថាប័ន។ ប្រព័ន្ធគណនេយ្យដែលគាំទ្រស្តង់ដាទាំងនេះ នឹងជួយសហគ្រាសសន្សំទាំងពេលវេលា និងថវិកា ដោយសារការធ្វើកំណត់ត្រា សង្ខេប និងរៀបចំរបាយការណ៍កាន់តែមានប្រសិទ្ធភាព ហើយវាផ្តល់ការបញ្ចូលទិន្នន័យយ៉ាងមានរបៀបរៀបរយ និងធានាថាទិន្នន័យគ្មានកំហុស។

- កាត់បន្ថយនូវកំហុសខុសឆ្គង ឬហានិភ័យនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងអង្គភាពអាជីវកម្ម ដោយការអនុវត្តស្របស្តង់ដាបានត្រឹមត្រូវ និងប្រើប្រព័ន្ធទំនើប អាជីវកម្មអាចកាត់បន្ថយកំហុសខុសឆ្គងស្ទើរតែទាំងស្រុង។
- ជួយសហគ្រាសពង្រឹងការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុលើការទិញ ការប្រើប្រាស់ និងចំណាយលើទ្រព្យសកម្មប្រកបដោយភាពច្បាស់លាស់ និងមានឯកសារសម្រិតសម្រាំងត្រឹមត្រូវ។ វាជួយទប់ស្កាត់អំពើពុករលួយ និងការបាត់បង់ទ្រព្យសកម្មដោយអចេតនា ឬចេតនា។
- ជួយសម្រួលការត្រួតពិនិត្យដោយសវនកម្មករ (Auditor) ការអនុវត្តត្រឹមត្រូវនូវ CIAS-16 អាចផ្តល់ឯកសារអះអាងបានយ៉ាងពេញលេញ និងច្បាស់លាស់សម្រាប់ការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើឡើងដោយ Auditor ។ វាបានកាត់បន្ថយនូវភាពស្មុគស្មាញ និងលើកកម្ពស់ភាពជឿជាក់ក្នុងការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ។
- ការអភិវឌ្ឍទិន្នន័យប្រចាំខែ ឬប្រចាំឆ្នាំស្របទៅតាមគោលការណ៍ធនាគារ និងសហគមន៍អន្តរជាតិសហគ្រាសអាចរៀបចំរបាយការណ៍លើ PPE ដោយមានទម្រង់ និងវិធីសាស្ត្រដែលបានទទួលស្គាល់ជាសកល ជួយឱ្យការទំនាក់ទំនងជាមួយភាគីផ្សេងៗដូចជា សហគមន៍អភិវឌ្ឍ ធនាគារជាតិ ឬអ្នកផ្តល់ប្រាក់កម្ចីកាន់តែងាយស្រួល។
- ការពង្រឹងភាពបើកចំហ និងការទទួលខុសត្រូវផ្នែកគ្រប់គ្រង CIAS-16 ជួយធានាថាការអភិរក្សទ្រព្យសកម្ម គឺជាសកម្មភាពមានភាពច្បាស់លាស់ និងត្រូវបានប្រកាសជាសាធារណៈ។ វាធ្វើឱ្យការគ្រប់គ្រងមានតម្លាភាព និងពង្រឹងភាពទំនួលខុសត្រូវ។
- ជួយលើការគ្រប់គ្រងចំណាយពន្ធ ដោយការរំលស់ និងការទទួលស្គាល់ impairment ត្រូវបានចុះបញ្ជីត្រឹមត្រូវ និងអាចប្រើប្រាស់ក្នុងការរាប់បញ្ចូលក្នុងរបាយការណ៍ពន្ធ ដូច្នេះវាអាចជួយកាត់បន្ថយនូវហានិភ័យពីសំណាក់អាជ្ញាធរពន្ធ និងការផាកពិន័យលើពន្ធ។
- ជួយក្នុងការរៀបចំផែនការវិនិយោគនាពេលអនាគត ព័ត៌មានទាំងអស់ដែលទាក់ទងនឹងអាយុកាលនៃទ្រព្យសកម្ម បំណុល និងតម្លៃសមស្របអាចប្រើប្រាស់សម្រាប់ការវិភាគ ផែនការវិនិយោគនាពេលអនាគត ដោយផ្អែកលើទិន្នន័យពិតប្រាកដ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ភាពខ្សោយនៅក្នុងការអនុវត្តស្របតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ តែងតែមានការកើតឡើងមួយចំនួនផងដែរ មិនថាស្តង់ដានេះ មានប្រសិទ្ធភាពកម្រិតណាក៏ដោយ វាក៏នូវតែមានចំណុចមិនល្អលេចឡើងផងដែរ។ ខាងក្រោមនេះជាចំណុចខ្សោយមួយចំនួននៅក្នុងការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ ៖

- មានភាពស្មុគស្មាញក្នុងការអនុវត្ត ដោយក្រុមហ៊ុនអាចជួបការលំបាកនៅក្នុងការយល់ដឹង និងអនុវត្តតាមស្តង់ដាដោយសារតម្រូវការលម្អិតខ្ពស់ ធ្វើឱ្យក្រុមហ៊ុននៅតែមានការយល់ខុស ឬអនុវត្តខុសពីបទប្បញ្ញត្តិ
- ការប្រើប្រាស់វិធីសាស្ត្រ Revaluation Model អាចបង្កើនហានិភ័យក្នុងការប៉ាន់ប្រមាណតម្លៃទីផ្សារនៃទ្រព្យសកម្ម ដោយវាអាចមានភាពអស្ថេរភាព ហើយត្រូវការអ្នកជំនាញក្នុងការវាយតម្លៃឱ្យបានត្រឹមត្រូវដែលអាចធ្វើ

ឱ្យការចំណាយមានការកើនឡើងផងដែរ

- ការយល់ដឹង និងសមត្ថភាពបច្ចេកទេសរបស់បុគ្គលិក ដោយគណនេយ្យករនៅកម្ពុជាមួយចំនួនមិនមានចំណេះដឹង និងសមត្ថភាពពេញលេញគ្រប់គ្រាន់ នៅក្នុងការអនុវត្តស្របទៅតាម CIAS-16 ដោយសារតែការអប់រំ និងការបណ្តុះបណ្តាលនៅមានកម្រិតកំណត់នៅឡើយ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយអំពីប្រធានបទ «សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦» រួចមកនេះ ក្រុមនាងខ្ញុំមានការយល់ឃើញថាស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ ពិតជាមានអត្ថប្រយោជន៍ និងសារៈសំខាន់យ៉ាងខ្លាំងដល់អ្នកសិក្សា អាជីវកម្ម និងសង្គមជាតិ។ ដោយបានធ្វើឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹងមួយ ដែលស្របតាមស្តង់ដាអន្តរជាតិ ចំណែកឯអាជីវកម្ម មានការអនុវត្តបានត្រឹមត្រូវនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ហើយការគ្រប់គ្រងទ្រព្យសកម្មបានក៏កាន់តែល្អប្រសើរ មិនសូវមាននូវកំហុសខុសឆ្គង និងហានិភ័យនៃការរាយការណ៍ហិរញ្ញវត្ថុ។ មិនតែប៉ុណ្ណោះ វាក៏បានជួយបង្កើននូវភាពជឿជាក់នៃរបាយការណ៍ហិរញ្ញវត្ថុដល់ភាគីពាក់ព័ន្ធ និងអ្នកផ្តល់កម្ចី ហើយជាក់ស្តែងការអនុវត្តបានត្រឹមត្រូវស្របតាមស្តង់ដាគណនេយ្យអន្តរជាតិ បានជួយធ្វើឱ្យប្រទេសជាតិ និងសង្គមជាតិមាននូវការរីកចម្រើនមួយកម្រិតផងដែរ។

ជាពិសេសទៅទៀត ការអនុវត្តស្របតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ បានធ្វើឱ្យការវិភាគប្រតិបត្តិការ ការកត់ត្រា ការជ្រើសរើសនូវវិធីសាស្ត្រដើម្បីគណនាតម្លៃទ្រព្យសកម្ម ការធ្វើរំលស់ទៅតាមអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ការធ្វើ Impairment បានយ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធិភាព ហើយវាក៏បានធ្វើឱ្យទិន្នន័យនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើការផ្សាយចេញទៅខាងក្រៅមានភាពត្រឹមត្រូវ ច្បាស់លាស់ និងអាចជឿទុកចិត្តបាន។ លើសពីនេះ ការអនុវត្ត CIAS-16 បានចង្អុលបង្ហាញអំពីចំណុចខ្លាំង ចំណុចខ្សោយ រួមទាំងផលប៉ះពាល់ក្នុងការអនុត្តផងដែរ។

ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ បានជួយសម្រួលទៅដល់ស្ថាប័ននៅក្នុងដំណើរការអាជីវកម្ម ដោយការប្រើប្រាស់នូវប្រព័ន្ធគណនេយ្យដែលមានប្រសិទ្ធិភាព បានជួយឱ្យចំណេញពេលវេលា និងថវិកាបានកាន់តែល្អប្រសើរ ហើយការរៀបចំនូវរបាយការណ៍ហិរញ្ញវត្ថុបានលឿន មានតម្លាភាព និងមានទំនុកចិត្តដល់អ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេស។

## ៥.២ ការផ្តល់អនុសាសន៍

នៅក្នុងអំឡុងពេលសិក្សាស្រាវជ្រាវ និងវិភាគលើឯកសារ ក៏ដូចជាទិន្នន័យដែលមានការពាក់ព័ន្ធទៅនឹងប្រធានបទ « សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ » រួចមក ដូចនេះហើយក្រុមយើងខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួន ដើម្បីធ្វើឱ្យការអនុវត្តនូវស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦ បានកាន់តែល្អប្រសើរ រួមមានដូចខាងក្រោម៖

- ដើម្បីជៀសវាងការកើតមានភាពស្មុគស្មាញចំពោះការអនុវត្ត CIAS-16 នោះស្ថាប័ននិយ័តករគណនេយ្យ និងសវនកម្ម (ACAR) ត្រូវធ្វើការបង្កើតនូវសៀវភៅណែនាំ និងលើកយកនូវឧទាហរណ៍ពិតៗជាក់ស្តែង ឬដោយប្រើភាសាងាយស្រួលយល់ ។ រៀបចំវគ្គបណ្តុះបណ្តាលជាក់លាក់ដើម្បីផ្តល់ការណែនាំ និងការឧបត្ថម្ភខាងបច្ចេកទេស ហើយបង្កើតនូវប្រព័ន្ធគាំទ្របច្ចេកទេស (Technical Support) ដូចជា Call center

ឬ Online helpdesk ដើម្បីឆ្លើយសំណួរក្នុងការអនុវត្ត CIAS-16។

- ដើម្បីជៀសវាងនូវហានិភ័យក្នុងការប៉ាន់ប្រមាណតម្លៃទីផ្សារនៃទ្រព្យសកម្ម នោះត្រូវធ្វើការចេញផ្សាយនូវវិធានការប្រកបដោយជំហានច្បាស់លាស់ ដើម្បីជួយសហគ្រាសប៉ាន់ប្រមាណតម្លៃ ដោយផ្អែកលើគោលការណ៍សហសម័យ និងតម្លៃទីផ្សារ។ រៀបចំក្រុមអ្នកវាយតម្លៃមានអាជ្ញាប័ណ្ណ និងឯកទេសដោយសហការជាមួយអង្គភាពជាន់ខ្ពស់ក្នុងវិស័យវាយតម្លៃ ដើម្បីធានាបាននូវការប៉ាន់ប្រមាណមានគុណភាព និងស្តង់ដា។
- ដើម្បីបង្កើននូវការយល់ដឹង និងសមត្ថភាពបច្ចេកទេសទៅដល់បុគ្គលិក នៅក្នុងការអនុវត្ត CIAS-16 នោះស្ថាប័នត្រូវជំរុញការរៀបចំវគ្គបណ្តុះបណ្តាលជាប្រចាំ សម្រាប់បុគ្គលិកគណនេយ្យ និងប្រធានហិរញ្ញវត្ថុទាំងក្នុងវិស័យរដ្ឋ និងឯកជន។ ផ្តល់ជំនួយហិរញ្ញវត្ថុ ឬអាហារូបករណ៍ សម្រាប់បុគ្គលិកគណនេយ្យទៅចូលរួមវគ្គអប់រំជំនាញវិស័យគណនេយ្យអន្តរជាតិ ហើយបង្កើតនូវកម្មវិធីប្រឡងបញ្ជាក់សមត្ថភាពជាសកល (Certifications) ដូចជា ACCA CPA ដែលត្រូវបានគាំទ្រដោយរដ្ឋាភិបាល ឬសហគ្រាសធំៗ។

# ឯកសារយោង


1. វិទ្យាស្ថានវ៉ាន់ដា (2022). Basic Financial Accounting : ភាគ១ បោះពុម្ពលើកទី១១ ទំព័រទី៧២-២៣២ ទំព័រ. ភ្នំពេញ។
2. វិទ្យាស្ថានវ៉ាន់ដា (2022). *Intermediate Accounting ភាគ១.* បោះពុម្ពលើកទី១១. ទំព័រទី០២. ១៦២ទំព័រ. ភ្នំពេញ។
3. វិទ្យាស្ថានវ៉ាន់ដា (2024). *Auditing ភាគ១.* បោះពុម្ពលើកទី១១. ទំព័រទី១៤. ៩៥ទំព័រ. ភ្នំពេញ។
4. វិទ្យាស្ថានវ៉ាន់ដា (2024). *Auditing ភាគ១.* បោះពុម្ពលើកទី១១ ទំព័រទី១៥-១៧. ៩៥ទំព័រ. ភ្នំពេញ។
5. និយ័តករគណនេយ្យ និងសវនកម្ម. (2021). *អំពីស្ថាប័ន.* Retrieved from https://www.acar.gov.kh (Accessed 02.04.25)
6. FaceBook Page. Khmer Next Generation. (2024,September 16). *ប្រវត្តិគណនេយ្យ.* Retrieved from
7. https://www.facebook.com/share/p/1AhtCkoxgG/?mibextid=wwXIfr (Accessed 02.04.25)
8. និយ័តករគណនេយ្យ និងសវនកម្ម. (2015,December 16). *ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១៦.* Retrieved from https://www.acar.gov.kh (Accessed 05.04.25)
9. ភ្នំពេញប៉ុស្តិ៍. (2020,October 26). *ហេតុអ្វីបានជាស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាមានសារៈសំខាន់ ?* Retrieved from https://m.postkhmer.com (Accessed 05.04.25)
10. និយ័តករគណនេយ្យ និងសវនកម្ម. (2015, December 16). *ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា.* Retrieved from https://www.acar.gov.kh (Accessed 05.04.25)

# ឧបសម្ព័ន្ធ


វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
ភាគ១
Intermediate Accounting
រក្សាសិទ្ធិគ្រប់យ៉ាងដោយ វិទ្យាស្ថាន វ៉ាន់ដា
បោះពុម្ពលើកទី១១(២០២២)
សម្រាប់ប្រើប្រាស់ផ្ទៃក្នុង

# វិទ្យាស្ថាន វ៉ាន់ដា
# VANDA INSTITUTE

ភាគ១



# សវនកម្ម
# Auditing

រក្សាសិទ្ធិគ្រប់យ៉ាងដោយ វិទ្យាស្ថាន វ៉ាន់ដា បោះពុម្ពលើកទី១១(២០២៤) សម្រាប់ប្រើប្រាស់ផ្ទៃក្នុង

# វិទ្យាស្ថាន វ៉ាន់ដា
# VANDA INSTITUTE

ភាគ១




# Basic Financial Accounting

រក្សាសិទ្ធិគ្រប់យ៉ាងដោយ វិទ្យាស្ថាន វ៉ាន់ដា បោះពុម្ពលើកទី១៣(២០២២) សម្រាប់ប្រើប្រាស់ផ្ទៃក្នុង

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 16

## ទ្រព្យ រោងចក្រ និងបរិក្ខារ

## Property, Plant and Equipment

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™